សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# តួនាទីអាជ្ញាសាលា
# នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ក. សៅ សុភ័ក្ត្រ**
**ក. ខូច សុវណ្ណី**

សាស្ត្រាចារ្យណែនាំ
លោក **ជិន វណ្ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ សៅ សុភ័ក្ត្រ និងឈ្មោះ ខូវ សុវណ្ណី ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២០ ក្នុងឆ្នាំសិក្សា ២០១៦-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំឱនកាយសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖**

លោកឪពុក **សៅ ឃួន - ខូវ សុចិត្រា** និងអ្នកម្តាយ **លី យៀម - ហេង សុខគីម** ដែលលោកមានគុណទាំងបួន បានផ្តល់កំណើត និងពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានកូនឱ្យប្រព្រឹត្តខ្លួនដើរតាមគន្លងធម៌ ព្រមទាំងទំនុកបម្រុងគ្រប់យ៉ាង ទាំងផ្នែកសម្ភារៈ និងស្មារតី ជាពិសេសលោកតែងតែនៅចាំលើកទឹកចិត្តដល់កូនទាំងការសិក្សា និងកិច្ចការផ្សេងៗទៀត តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនៅសាលកវិទ្យាល័យ ហើយទទួលបានជោគជ័យដោយមោទនភាព។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រីសាស្ត្រាចារ្យទាំងឡាយ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលលោកបានខិតខំបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ ក៏ដូចជានិស្សិតគ្រប់គ្នា អស់ពីកម្លាំងកាយចិត្ត ដោយការយកចិត្តទុកដាក់នូវគ្រប់មុខវិជ្ជាដ៏មានតម្លៃ និងព្រមទាំងណែនាំអំពីផ្លូវល្អៗដល់រូបយើងខ្ញុំ ដើម្បីទុកជាអាវុធ ដ៏មានប្រសិទ្ធភាពសម្រាប់កែលម្អជីវិតទៅថ្ងៃអនាគត។

ជាពិសេសទៅទៀតនេះ យើងខ្ញុំសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្រៃលែងជូនចំពោះ **លោកសាស្ត្រាចារ្យ ជិន វណ្ណារ៉ា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ដើម្បីធ្វើការណែនាំបង្ហាត់បង្ហាញផ្តល់យោបល់ និងផ្តល់នូវវិធីសាស្ត្រល្អៗក្នុងការសរសេរសារណា ព្រមទាំងជួយកែលម្អនូវរាល់ចំណុចខ្វះខាតទាំងឡាយណា ដែលជាប្រយោជន៍ដល់ការសរសេរសារណារបស់យើងខ្ញុំឱ្យបានល្អប្រសើរ រហូតចងក្រងបានជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

សូមអរគុណចំពោះ **លោក ណុប សាវុទ្ធ** ជាអាជ្ញាសាលានៃសាលាដំបូងខេត្តកណ្តាល ដែលបានជួយណែនាំផ្តល់នូវមតិយោបល់ និងជួយផ្តល់នូវឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចការស្រាវជ្រាវនេះ។

ជាទីបញ្ចប់យើងខ្ញុំ សូមប្រសិទ្ធិពរជ័យជូនចំពោះ លោកឪពុក អ្នកម្តាយ ឯកឧត្តម លោកជំទាវ លោក-លោកស្រី សាស្ត្រាចារ្យទាំងអស់ សូមឱ្យលោកជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន សុខភាពរឹងមាំ ជាពិសេសសូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងសូមឱ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រយៈពេលបួនឆ្នាំ នៅក្នុងការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានកន្លងផុតទៅយ៉ាងឆាប់រហ័ស។ នៅពេលជាមួយគ្នានេះ ការសិក្សាក៏បានឱ្យនិស្សិតគ្រប់រូបទទួលបាននូវចំណេះដឹងថ្មីៗជាច្រើន ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ-អ្នកគ្រូ និងសាស្ត្រាចារ្យទាំងឡាយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដោយបានជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជួយជម្រុញការអភិវឌ្ឍន៍ប្រទេសជាតិឱ្យឈានទៅរកវឌ្ឍនភាព និងភាពសម្បូររុងរឿងដូចបណ្តាប្រទេសនានានៅលើសាកលលោក។

ដើម្បីឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់លោកគ្រូ-អ្នកគ្រូ និងសាស្ត្រាចារ្យទាំងឡាយ ក៏ដូចជាការបំពេញនូវតម្រូវការចាំបាច់របស់សាកលវិទ្យាល័យ ដែលតម្រូវឱ្យនិស្សិតដែលទទួលបាននូវចំណាត់ថ្នាក់តាមការកំណត់របស់សាកលវិទ្យាល័យត្រូវរៀបចំធ្វើជាសារណា ឬរបាយការណ៍នៅពេលបញ្ចប់ការសិក្សា និងដើម្បីទុកជាស្នាដៃ ក៏ដូចជាឯកសារសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយបានធ្វើការស្រាវជ្រាវបន្ថែមផងដែរ។ ការសិក្សាស្រាវជ្រាវ ក៏ដូចជាការចងក្រងដ៏ពិបាក ដើម្បីទទួលបាននូវសារណាមួយនេះ គឺពិតជាធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើនទាក់ទងទៅនឹងការគិតនូវគំនិត ដើម្បីច្នៃប្រឌិតនូវអ្វីមួយដែលថ្មីសម្រាប់ខ្លួនយើងខ្ញុំផ្ទាល់ ហើយក៏ដើម្បីជាផលប្រយោជន៍សម្រាប់អ្នកសិក្សាដទៃទៀតដែរ ជាពិសេសគឺនិស្សិត និងអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត សម្រាប់យកវាទុកជាការវិភាគមួយក្នុងការស្រាវជ្រាវនូវអត្ថបទ ឬបញ្ហាគតិយុត្តនានាដែលទាក់ទងនឹងតួនាទីរបស់អាជ្ញាសាលា។

សារណាដែលមានឈ្មោះថា "**តួនាទីអាជ្ញាសាលានៅព្រះរាជាណាចក្រកម្ពុជា**" ដែលមិត្តអ្នកអានកំពុងកាន់ក្នុងដៃនេះ គឺជាសារណាមួយដែលបានធ្វើឡើង ដោយការខិតខំប្រឹងប្រែងរបស់យើងខ្ញុំអស់រយៈពេលជិត ៦ ខែ។ បុព្វហេតុដែលនាំឱ្យយើងខ្ញុំជ្រើសរើសប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវគឺ ព្រោះតែវិជ្ជាជីវៈអាជ្ញាសាលានេះ គឺជាវិជ្ជាជីវៈមួយដែលកម្រនឹងមានអ្នកបានដឹង និងបានស្គាល់អំពីវិជ្ជាជីវៈនេះណាស់ ជាក់ស្តែងនិស្សិតច្បាប់យើងតែម្តង។ យើងខ្ញុំសង្ឃឹមថា អត្ថបទដ៏តិចតួចស្តួចស្តើងមួយនេះ អាចបង្ហាញអំពីតួនាទីដ៏កម្រមានអ្នកដឹងមួយនេះ ឱ្យអ្នកបានយល់ដឹងអំពីតួនាទីរបស់អាជ្ញាសាលា។

ដោយសារតែសារណានេះជាស្នាដៃដំបូងរបស់យើងខ្ញុំទាំងពីរ ហើយទោះបីជាយើងខ្ញុំខិតខំស្វែងរកនូវឯកសារដ៏សំខាន់ជាច្រើន ដែលទាក់ទងនឹងប្រធានបទនេះយកមកសរសេររៀបរៀងជាសារណានេះក៏ដោយ ក៏យើងខ្ញុំគិតថាសារណានេះនៅមានចំណុចខ្វះចន្លោះ ជាពិសេសទៅលើពាក្យពេចន៍អក្ខរាវិរុទ្ធ និងខ្លឹមសារពុំទាន់បានស៊ីជម្រៅ និងបានត្រឹមត្រូវមួយរយភាគរយនោះទេ ដែលនឹងធ្វើឱ្យអ្នកទាំងអស់គ្នាកើតឡើងនូវចម្ងល់នៅពេលអ្នកអានសារណាមួយនេះ។ ហេតុដូច្នេះហើយ នៅរាល់កំហុសដែលកើតឡើងដោយអចេតនានៅក្នុងសារណារបស់យើងខ្ញុំនេះ យើងខ្ញុំសូមអភ័យទោសទុកជាមុន ហើយយើងខ្ញុំសូមស្វាគមន៍ និងរងចាំនូវរាល់ការរិះគន់ដើម្បីស្ថាបនានៅរាល់កំហុសទាំងនោះ ដោយក្តីរីករាយបំផុត។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**ការបញ្ជូនដំណឹងតាមផ្លូវតុលាការ**

**ផ្នែកទី១ ៖ ការបញ្ជូនដំណឹងក្នុងរឿងរដ្ឋប្បវេណី** ........ ៤

**កថាខណ្ឌទី១ ៖ គោលការណ៍នៃការបញ្ជូន** ........ ៤

ក. និយមន័យ ........ ៤

ខ. មន្ត្រីទទួលបន្ទុកការបញ្ជូន ........ ៤

**កថាខណ្ឌទី២ ៖ ការប្រតិបត្តិការបញ្ជូន** ........ ៦

ក. ប្រភេទនៃការបញ្ជូន ........ ៦

ខ. របាយការណ៍អំពីការបញ្ជូន ........ ១១

**ផ្នែកទី២ ៖ ការបញ្ជូនដំណឹងក្នុងរឿងព្រហ្មទណ្ឌ** ........ ១៣

**កថាខណ្ឌទី១ ៖ ការបញ្ជូនដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់** ........ ១៣

ក. ការប្រគល់ដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់ ........ ១៣

ខ. រយៈពេលដែលត្រូវកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់ ........ ១៤

**កថាខណ្ឌទី២ ៖ ការបញ្ជូនដីកាកោះហៅជនជាប់ចោទ និងជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ** ........ ១៤

ក. ការប្រគល់ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ ........ ១៤

ខ. ការប្រគល់ដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ ........ ១៥

គ. រយៈពេលកោះហៅចូលរួមសវនាការ ........ ១៥

**កថាខណ្ឌទី៣ ៖ ការបញ្ជូនដីកាបង្គាប់ឱ្យចូលខ្លួន និងការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ** ........ ១៦

ក. ការបញ្ជូនដីកាបង្គាប់ឱ្យចូលខ្លួន ........ ១៦

ខ. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ........ ១៦

គ. ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចជូនដល់ភាគីពាក់ព័ន្ធ ........ ១៦

## ជំពូកទី២

## ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

**ផ្នែកទី១ ៖ ស្ថាប័នអនុវត្តសេចក្តីសម្រេចរបស់តុលាការ** ........ ១៨

**កថាខណ្ឌទី១ ៖ តួនាទីមុនពេលចាប់ផ្តើមការរឹបអូសចលនវត្ថុ** ........ ១៨

ក. នីតិវិធីដាក់ពាក្យសុំ ........ ១៨

ខ. តួនាទីមុនពេលចាប់ផ្តើមរឹបអូសចលនវត្ថុ ........ ២០

**កថាខណ្ឌទី២ ៖ តួនាទីនាពេលរឹបអូសចលនវត្ថុ** ........ ២១

ក. ការរឹបអូសចលនវត្ថុ ........ ២១

ខ. ការរួមបញ្ចូលរឿងក្តី ........ ២៣

គ. ចលនវត្ថុដែលបានទទួលយកពីតតិយជន ........ ២៤

ឃ. ការហាមឃាត់ និងការលុបចោលការរឹបអូស ........ ២៥

**កថាខណ្ឌទី៣ ៖ តួនាទីក្រោយពេលរឹបអូសចលនវត្ថុ(ពេលលក់ចលនវត្ថុ)** ........ ២៥

ក. វិធីលក់ ........ ២៥

ខ. ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់ ........ ២៦

គ. ការលក់នៅក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក ........ ២៧

ឃ. ការចែកចំណែក ........ ២៧

**ផ្នែកទី២ ៖ ជំនួយឱ្យតុលាការអនុវត្ត** ........ ២៩

**កថាខណ្ឌទី ១ ៖ ការអនុវត្តតាមការចាត់តាំងរបស់តុលាការអនុវត្ត** ........ ២៩

ក. តួនាទីក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗទៀត ........ ៣០

ខ. តួនាទីក្នុងការអនុវត្តចំពោះអចលនវត្ថុ ........ ៣៣

គ. តួនាទីក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ........ ៣៦

**កថាខណ្ឌទី ២ ៖ ការអនុវត្តតាមការចាត់តាំងរបស់សាលាដំបូងក្នុងការចាត់ចែងរក្សាការពារ** ........ ៣៨

ក. ស្ថាប័នចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន ........ ៣៨

ខ. ប្រភេទនៃការចាត់ចែងរក្សាការពារ ..... ៣៨
គ. សោហ៊ុយនៃការចាត់ចែងរក្សាការពារ ..... ៣៩
ឃ. ការអនុវត្តរក្សាការពារ ..... ៤០
ង. អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ..... ៤៥
**សេចក្តីសន្និដ្ឋាន** ..... ៤៦
**អនុសាសន៍** ..... ៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

នៅប្រទេសកម្ពុជា អាជ្ញាសាលាត្រូវបានបង្កើតឡើងជាលើកដំបូងនៅឆ្នាំ១៩៣៨ ដែលស្ថិតនៅក្រោមលក្ខន្តិកៈអាជ្ញាសាលា ដែលប្រកាសដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៣៨ ដែលមានចំនួន ៥១ មាត្រា។ ក្នុងអំឡុងពេលនោះលក្ខន្តិកៈស្ដីពីអាជ្ញាសាលា គឺស្ថិតនៅក្នុងសម័យអាណានិយមបារាំង ហើយបន្តរហូតដល់សម័យព្រះរាជាណាចក្រកម្ពុជាទី ១ (សង្គមរាស្ត្រនិយម)។ ចាប់ពីសម័យសាធារណៈខ្មែររហូតដល់សម័យព្រះរាជាណាចក្រកម្ពុជាលើកទី ២ (បច្ចុប្បន្ន) លក្ខន្តិកៈស្ដីពីអាជ្ញាសាលា ត្រូវបានបំផ្លិចបំផ្លាញចោលស្ទើរតែទាំងស្រុង និងលែងមានមន្ត្រីដែលបម្រើការងារជាអាជ្ញាសាលានេះតទៅទៀត។

បន្ទាប់ពីសង្គ្រាមស៊ីវិល នៅប្រទេសកម្ពុជាត្រូវបានបញ្ចប់ដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកដំបូងសម្រាប់អាណត្តិទី ១ ។ បន្ទាប់មកសភាធម្មនុញ្ញ បានបង្កើតរៀបចំតាក់តែង និងអនុម័តនូវរដ្ឋធម្មនុញ្ញថ្មី សម្រាប់ប្រទេសកម្ពុជានៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី ២ រហូតប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

ក្រោយមកនៅឆ្នាំ២០០៦ ក្រមនីតិវិធីរដ្ឋប្បវេណីថ្មី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចាប់ផ្ដើមលេចចេញជារូបរាង និងត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។ ពាក្យ អាជ្ញាសាលា ត្រូវបានគេប្រើប្រាស់ជាថ្មី នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនេះ ហើយក៏បង្កើតនូវវិជ្ជាជីវៈអាជ្ញាសាលា ឱ្យមាននៅក្នុងសង្គមកម្ពុជាជាលើកទី ២។

ថ្វីត្បិតតែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ឃើញមានប្រើពាក្យអាជ្ញាសាលាក៏ពិតមែន ប៉ុន្តែមន្ត្រីដែលនឹងបំពេញតួនាទីជាអាជ្ញាសាលា មិនទាន់ត្រូវបានបង្កើតអានុភាពឱ្យបានពេញលេញនៅឡើយទេ ដែលជាហេតុធ្វើឱ្យមានការរាំងស្ទះក្នុងការអនុវត្តនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌ។ ដោយមើលឃើញបញ្ហាប្រឈមបែបនេះហើយ ទើបក្រសួងយុត្តិធម៌បានចេញនូវប្រកាសលេខៈ ៣០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ដោយប្រគល់តួនាទីអាជ្ញាសាលា ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ទៅឱ្យព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង នៅតាមសាលាដំបូងរាជធានី-ខេត្ត ជាបណ្ដោះអាសន្ន រហូតដល់មានច្បាប់ស្ដីពីលក្ខន្តិកៈអាជ្ញាសាលា។

ដោយឃើញពីការកង្វះខាតនូវមន្ត្រីអាជ្ញាសាលាបែបនេះ សាលាភូមិន្ទអាជ្ញាសាលា ក៏ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខៈ ១១៦ អនក្រ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ដែលមាន **ឯកឧត្តម អ៊ុក ទូច** ជានាយកសាលា ដោយព្រះរាជក្រឹត្យលេខៈ នស/រកត/០៩០៨/១០៣០ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង **ឯកឧត្តម អ៊ុក ទូច** ជានាយកសាលាភូមិន្ទអាជ្ញាសាលានៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ការណ៍នេះសាលាភូមិន្ទអាជ្ញាសាលា ស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់រាជបណ្ឌិត

សភាវិជ្ជាជីវៈតុលាការ ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខៈ នស/រកក/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥។

ក្នុងនោះដែរ ដើម្បីបន្តសកម្មភាពរបស់ខ្លួន និងបំពេញនូវវិជ្ជាជីវៈអាជ្ញាសាលា ដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ **សម្តេចវិបុលបញ្ញា សុខអាន** ជាអតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សារាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានចេញប្រកាសលេខៈ ១៥៩ ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការប្រឡងជ្រើសរើសសិស្សអាជ្ញាសាលាជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ហើយក៏មានបេក្ខជនបានមកដាក់ពាក្យចូលរួមការប្រឡង មានចំនួន ៣៣៣ នាក់។ រហូតមកដល់ថ្ងៃទី ១១-១២ និង ១៣ ខែធ្នូ ឆ្នាំ២០១២ ទើបរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សអាជ្ញាសាលាជំនាន់ទី ១ ដែលជាលទ្ធផលមានបេក្ខជនចំនួន ៣១ រូប បានជាប់ជាស្ថាពរ ក្នុងនោះមានបេក្ខភាព ២ រូបជាស្ត្រី ប៉ុន្តែនៅពេលចូលរួមទទួលការបណ្តុះបណ្តាលមានតែបេក្ខភាព ២៨ រូបទេ ដែលបានចូលរួម និងក្លាយជាសិស្សអាជ្ញាសាលាជំនាន់ទី ១ នៃសាលាភូមិន្ទអាជ្ញាសាលា តាមប្រកាសលេខៈ ១៨ ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការតែងតាំងសិស្សអាជ្ញាសាលាជំនាន់ទី ១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ហើយមកដល់បច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា នូវមិនទាន់ក្លាយជាច្បាប់ជាធរមាននៅឡើយទេ។

សាលាភូមិន្ទអាជ្ញាសាលា ត្រូវបានបង្កើតឡើង និងមានតួនាទីដ៏សំខាន់នៅក្នុងការបណ្តុះបណ្តាលចំណេះដឹងវិជ្ជាជីវៈដល់អាជ្ញាសាលា។ ការបង្កើតស្ថាប័នអាជ្ញាសាលាមានគោលបំណងធ្វើឱ្យប្រព័ន្ធយុត្តាធិការឱ្យមានដំណើរការល្អ ជួយរំលែកបន្ទុកការងារតុលាការមួយផ្នែក និងធ្វើឱ្យការងារមានប្រសិទ្ធភាពប្រកបដោយជំនាញច្បាស់លាស់ ជួយជម្រុញសេវាយុត្តិធម៌របស់តុលាការកាន់តែប្រសើរឡើង និងផ្តល់នូវជំនឿទុកចិត្តទៅដល់សាធារណៈជន និងជម្រុញឱ្យប្រព័ន្ធយុត្តាធិការកាន់តែទទួលបាននូវជំនឿទុកចិត្តខ្ពស់ ដូចប្រព័ន្ធយុត្តាធិការនៃប្រទេសនីតិរដ្ឋដទៃទៀត។

នៅក្នុងស្ថាប័នអាជ្ញាសាលា មានមន្ត្រីដែលបម្រើការងារមានឈ្មោះថា អាជ្ញាសាលា។ ដោយយោងតាមសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី កថាភាគទី ៣ អាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យមួយដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការ(មាត្រា២៤៦ កថាខណ្ឌទី៣) និងធ្វើការអនុវត្ត ដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។ ចំណែកឯការពន្យល់នៅក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជជួន ណាត អាជ្ញាសាលា គឺជាអ្នកដែលរាជការតាំងឱ្យមានមុខងារជាជំនួយតុលាការ(អាជ្ញាសាលាទទួលបានផលប្រយោជន៍ពីគូក្តីតាមកំណត់ដែលច្បាប់អនុញ្ញាតឱ្យយក)។ អាជ្ញាសាលា គឺមន្ត្រីរាជការដែលត្រូវតែងតាំងឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌(មាត្រា៨ថ្មី នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា) ហើយ

អាជ្ញាសាលាត្រូវទទួលប្រាក់បៀវត្សរ៍ និងមួយផ្នែកទៀតនៃកម្រៃដែលត្រូវបង់ចូលជាថវិការដ្ឋចំពោះការអនុវត្តមុខងាររបស់ខ្លួន ចំពោះកម្រៃមួយផ្នែកដែលអាជ្ញាសាលាត្រូវទទួលបាន ត្រូវបានកំណត់ដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌(មាត្រា១០ថ្មី នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា)។ ដោយសារតែវិជ្ជាជីវៈអាជ្ញាសាលាត្រូវបានបោះបង់ចោលជាយូរណាស់មកហើយ ហើយទើបតែបង្កើតឡើងនាពេលថ្មីៗនេះ ហេតុនេះហើយបានជាមាននិស្សិតច្បាប់ ក៏ដូចជាអ្នកសិក្សាមួយចំនួនមាននូវចម្ងល់និងសំណួរចោទសួរឡើងថាៈ តើអាជ្ញាសាលាត្រូវបំពេញនូវតួនាទីអ្វីខ្លះ? ជាមួយគ្នានឹងនេះដែរ តើការអនុវត្តសេចក្តីសម្រេចតុលាការមានលក្ខណៈយ៉ាងដូចម្តេច? ជាបន្តទៅទៀតនេះយើងនឹងធ្វើការសិក្សាអំពីៈ

**ជំពូកទី១ : ការបញ្ជូនដំណឹងតាមផ្លូវតុលាការ**

**ជំពូកទី២ : ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ**

# ជំពូកទី ១

# ការបញ្ជូនដំណឹងតាមផ្លូវតុលាការ

ដើម្បីឱ្យការបញ្ជូនលិខិត ឯកសារ ឬដីកាផ្សេងៗរបស់តុលាការបានដល់ដៃអ្នកដែលត្រូវទទួល ដូចជាភាគី ឬអ្នកដែលពាក់ព័ន្ធនៅក្នុងរឿងក្តី ហើយដើម្បីឱ្យការបញ្ជូននេះមានប្រសិទ្ធភាពទាមទារឱ្យស្ថាប័នមួយដែលទទួលបន្ទុកកិច្ចការបញ្ជូននេះឱ្យបានច្បាស់លាស់។ ការបញ្ជូនដំណឹងតាមផ្លូវតុលាការ ត្រូវបានចែកចេញជាពីរប្រភេទ គឺ **ការបញ្ជូនដំណឹងក្នុងរឿងរដ្ឋប្បវេណី**(ផ្នែកទី១) និង**ការបញ្ជូនដំណឹងក្នុងរឿងព្រហ្មទណ្ឌ**(ផ្នែកទី២)។

## ផ្នែកទី១ ៖ ការបញ្ជូនដំណឹងក្នុងរឿងរដ្ឋប្បវេណី

នៅក្នុងរឿងរដ្ឋប្បវេណី ដើម្បីឱ្យការបញ្ជូនមានប្រសិទ្ធភាព ទាមទារឱ្យមាននូវការគោរពនូវគោលការណ៍នៃការបញ្ជូន និងស្ថាប័នជំនាញមួយដែលជាក់លាក់ ហើយដែលស្ថាប័ននេះត្រូវទទួលបន្ទុកប្រតិបត្តិនីតិវិធីនៃការបញ្ជូន។

### កថាខណ្ឌទី១ ៖ គោលការណ៍នៃការបញ្ជូន

#### ក. និយមន័យ

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍នៅក្នុងរឿងក្តីផ្សេងៗ។ ការបញ្ជូននេះអាចជាការបញ្ជូនពាក្យបណ្តឹង លិខិត ឬដីកាផ្សេងៗរបស់តុលាការរដ្ឋប្បវេណី និងតុលាការព្រហ្មទណ្ឌ។ ដូច្នេះការបញ្ជូនត្រូវស្ថិតនៅក្រោមសិទ្ធិរបស់តុលាការជានិច្ច ជាគោលការណ៍ការបញ្ជូនអាចត្រូវបានធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ ឬដោយការប្រគល់។

#### ក.១. គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ

ការបញ្ជូនដោយដោយឆន្ទានុសិទ្ធិ[1] គឺជាសិទ្ធិពិសេសរបស់ចៅក្រម ដែលតាមរយៈសិទ្ធនេះ ចៅក្រមពុំចាំបាច់សួរយោបល់ពីភាគីពាក់ព័ន្ធណាមួយឡើយ ពោលគឺចៅក្រមមានសិទ្ធិចាត់ចែងការបញ្ជូនពាក្យបណ្តឹង លិខិត ឯកសារ ឬដីកាផ្សេងៗរបស់តុលាការដោយឆន្ទៈផ្ទាល់របស់គាត់ ប្រសិនបើគាត់យល់ឃើញថាចាំបាច់។ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ណាមួយបានចែង ដូចជាការបញ្ជូនតាមការផ្សាយជាសាធារណៈ ឬការបញ្ជូនតាមទូតដែលមានកិច្ចព្រមព្រៀងពិសេស ជាអាទិ៍ ក្នុងករណីនេះចៅក្រមមិនអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនបានឡើយ ពោលគឺគាត់ត្រូវគោរពនូវលក្ខខណ្ឌការបញ្ជូនតាមការផ្សាយជាសាធារណៈដែលច្បាប់បានកំណត់ ឬតាមការបញ្ជូនតាមទូតដែលមានកិច្ចព្រមព្រៀងពិសេស។

[1] មាត្រា២៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

**ក.២. គោលការណ៍នៃការបញ្ជូនដោយការប្រគល់**

ការបញ្ជូនដោយការប្រគល់ គឺត្រូវធ្វើឡើងដោយការប្រគល់នូវឯកសារដែលត្រូវបញ្ជូននោះ ទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះដោយផ្ទាល់ដៃ ឬដល់ដៃជននោះតែម្តង លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ដូចជា ករណីនៃការបញ្ជូនដោយបង្គ្រប់កិច្ច ការបញ្ជូនដោយទុកចោល ការបញ្ជូនទៅបរទេស ឬការបញ្ជូនតាមការផ្សាយជាសាធារណៈ ជាអាទិ៍។ ការបញ្ជូនទាំងនោះ ទាមទារឱ្យមានការគោរពនូវលក្ខខណ្ឌនីមួយៗនៃការបញ្ជូនឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

ដោយឡែកឯកសារដែលត្រូវបញ្ជូន គឺអ្នកដែលត្រូវទទួលបន្ទុកការបញ្ជូន ឬប្រតិបត្តិការបញ្ជូន ត្រូវតែយកឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូន ហើយរក្សាទុកនូវឯកសារដើម លើកលែងតែក្នុងករណីមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ដែលតម្រូវឱ្យបញ្ជូននូវឯកសារដើម ដូចជាការបញ្ជូនលិខិតសាលក្រម ជាអាទិ៍។

ក្នុងករណីប្រសិនបើអ្នកដែលទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃឯកសារ នៅពេលប្រគល់ឯកសារនោះ ដើម្បីជាប្រយោជន៍ឱ្យបានយល់នូវខ្លឹមសារ និងអាចធ្វើការតវ៉ាតាមបញ្ញត្តិច្បាប់[2]។

**ខ. មន្ត្រីទទួលបន្ទុកការបញ្ជូន**

ស្ថាប័នដែលត្រូវធ្វើការបញ្ជូន គឺមានមន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន(ស្ថាប័នចាត់ចែងកិច្ចការបញ្ជូន) និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន(ស្ថាប័នប្រតិបត្តិការបញ្ជូន)។

**ខ.១. មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន(ស្ថាប័នចាត់ចែងកិច្ចការបញ្ជូន)**

មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន គឺជាក្រឡាបញ្ជី[3]។ មុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូននេះ គឺជាការធ្វើ ឬការផ្តល់នូវសេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូន ហើយប្រគល់អំណាចនៃការបញ្ជូនឯកសារនោះទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន និងត្រូវយករបាយការណ៍នៃការបញ្ជូននេះជូនចៅក្រម ដើម្បីឱ្យចៅក្រមពិនិត្យ ថាតើការបញ្ជូននេះត្រឹមត្រូវហើយឬនៅ ដូចជាការជូនដំណឹងដល់ចៅក្រមអំពីបញ្ហាផ្សេងៗជុំវិញនីតិវិធីបញ្ជូនជាដើម។ ហើយជាចុងក្រោយ មន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន(ក្រឡាបញ្ជី) ត្រូវរក្សាទុករបាយការណ៍នៃការបញ្ជូននេះទុកក្នុងសំណុំរឿង ដោយរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវទៅតាមកាលបរិច្ឆេទនៃលំដាប់ឯកសារ។

[2] មាត្រា២៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[3] មាត្រា២៤៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីដដែល

**ខ.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន( ស្ថាប័នប្រតិបត្តិការបញ្ជូន )**

មន្ត្រីទទួលបន្ទុកប្រតិបត្តិការការបញ្ជូនមានដូចជា មន្ត្រីបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលាក្រឡាបញ្ជី[4]។ មុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺការបញ្ជូនដោយផ្ទាល់ចំពោះជនដែលត្រូវទទួលការបញ្ជូន ដូចជាត្រូវបញ្ជូននូវខ្លឹមសារ ឬឯកសារណាមួយទៅបុគ្គលជាក់លាក់ណាម្នាក់ដែលបានកំណត់ បន្ទាប់មកត្រូវធ្វើរបាយការណ៍អំពីការបញ្ជូនទៅតុលាការដែលជាតុលាការដើម(ការបញ្ជូនបានសម្រេច) ចំពោះការបញ្ជូន ត្រូវតែបញ្ជូននូវឯកសារថតចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែករណីដែលបានកំណត់ពិសេសក្នុងច្បាប់។ ដោយឡែក ប្រសិនបើនៅក្នុងករណីដែលបានព្យាយាមបញ្ជូន តែការបញ្ជូននោះធ្វើឡើងពុំបានសម្រេចនោះទេ មន្ត្រីដែលត្រូវទទួលបន្ទុកនៃការបញ្ជូនក៏ត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និងចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រានេះ ជូនទៅតុលាការផងដែរ[5]។

**ខ.៣. ឯកសារដែលត្រូវធ្វើការបញ្ជូន**

ឯកសារដែលច្បាប់បានកំណត់ឱ្យធ្វើការបញ្ជូនមានដូចជា៖

- ពាក្យបណ្តឹង
- ពាក្យសុំបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង
- អនុសារសាលក្រម
- ពាក្យបណ្តឹងទាស់
- លិខិតដកពាក្យបណ្តឹង
- ដីកាសម្រេចចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ
- ដីកាសម្រេចរក្សាការពារ

**កថាខណ្ឌទី២ ៖ ការប្រតិបត្តិការបញ្ជូន**

មន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូន នឹងត្រូវអនុវត្តកិច្ចការបញ្ជូនរបស់ខ្លួនទៅតាមប្រភេទផ្សេងៗនៃការបញ្ជូន បន្ទាប់មកត្រូវធ្វើរបាយការណ៍នោះ ទៅកាន់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនវិញ(ក្រឡាបញ្ជី)។

**ក. ប្រភេទនៃការបញ្ជូន**

នៅពេលធ្វើការបញ្ជូន អាជ្ញាសាលាអាចធ្វើតាមវិធីមួយចំនួនទៅតាមប្រភេទដែលច្បាប់បានកំណត់ ដែលវាអាស្រ័យទៅតាមស្ថានភាពនីមួយៗ នៅពេលបំពេញតួនាទីរបស់ខ្លួនទៅឱ្យជនដែលត្រូវទទួលនូវការបញ្ជូននោះដោយប្រភេទនៃការបញ្ជូនទាំងនោះមានដូចជា៖

[4] មាត្រា២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[5] មាត្រា២៥៤ នៃក្រមនីតិវិធីដដែល

### ក.១. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង

បុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង សំដៅទៅលើបុគ្គលដែលមិនអាចធ្វើសកម្មភាពបណ្តឹងបាន បុគ្គលទាំងនោះមានដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ជាអាទិ៍ មូលហេតុដែលច្បាប់ហាមឃាត់នូវបុគ្គលទាំងនេះ ក្នុងគោលដៅដើម្បីការពារនូវផលប្រយោជន៍របស់ពួកគេ។ នៅពេលដែលមានការបញ្ជូនឯកសារដែលត្រូវបញ្ជូនទៅបុគ្គលទាំងនោះ គឺត្រូវធ្វើការបញ្ជូនទៅចំពោះអ្នកតំណាង ដែលច្បាប់បានកំណត់ មានដូចជា អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈជាដើម។ ប៉ុន្តែក្នុងករណីអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ គឺជាករណីដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យអនីតិជនចាត់ចែងទ្រព្យមួយចំនួន និងករណីដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យអនីតិជននោះប្រកបអាជីវកម្មបាន។ ម្យ៉ាងទៀត ចំពោះអនីតិជនដែលទទួលបាននូវអត្តាធិនភាព អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានដោយមិនចាំបាច់ឆ្លងកាត់អ្នកតំណាងដែលច្បាប់បានកំណត់ ការទទួលបាននូវអត្តាធិនភាពនេះមានលក្ខណៈគតិយុត្តតាមផ្លូវច្បាប់ ដោយមានន័យថាជននោះអាចក្លាយជាសមត្ថជនបាន។ ប៉ុន្តែចំពោះសមត្ថភាពនៅក្នុងការធ្វើបណ្តឹងនេះ បានត្រឹមតែបណ្តឹងដែលទាក់ទងនឹងជំនួញដែលបានអនុញ្ញាតនោះតែប៉ុណ្ណោះ។ ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាងរួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅចំពោះតែជនណាម្នាក់ជាការគ្រប់គ្រាន់។ រីឯការបញ្ជូនទៅបុគ្គលដែលជាប់ពន្ធនាគារវិញ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ត្រូវធ្វើការបញ្ជូននៅចំពោះមុខប្រធានពន្ធនាគារ[6]។

### ក.២. ការបញ្ជូនដោយការប្រគល់

ការបញ្ជូនដោយការប្រគល់ ជាគោលការណ៍ត្រូវប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលការបញ្ជូន។ ហើយត្រូវបញ្ជូនទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និងទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន ប៉ុន្តែចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់សាមីខ្លួនបាន[7]។ ដោយឡែកចំពោះការបញ្ជូនទៅទីកន្លែងដែលត្រូវបញ្ជូន ឬអ្នកដែលទទួលការបញ្ជូន ត្រូវបញ្ជូនទៅទីកន្លែងដែលបានជូនដំណឹងនោះ ឧទាហរណ៍ៈ ដើមចោទឈ្មោះ ក មានការជូនដំណឹងអំពីអាសយដ្ឋានដែលត្រូវធ្វើការជូនដំណឹងបែបនេះ(ទីលំនៅផ្លូវលេខ២៣៧ ផ្ទះលេខ៣៨ សង្កាត់អូរឡាំពិច ខណ្ឌចំការមន រាជធានីភ្នំពេញ) ដូច្នេះអាចធ្វើការបញ្ជូនទៅលំនៅឋានដូចដែលបានកំណត់នេះ។ ហើយរាល់ការជូនដំណឹងដូចដែលបានរៀបរាប់ខាងលើនេះ ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ[8]។

---

[6] មាត្រា២៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[7] មាត្រា២៤៩ នៃក្រមនីតិវិធីដដែល

[8] មាត្រា២៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីដដែល

### គ.៣. ការបញ្ជូនដោយការជួបប្រទះ

ទោះបីជាមានគោលការណ៍នៃការបញ្ជូនត្រូវធ្វើនៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូនក៏ដោយ ប៉ុន្តែប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះ ពុំច្បាស់លាស់ថាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើនៅកន្លែងដែលបានជួបជននោះបាន លើកលែងតែមានករណីដែលភាគីបានជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូននោះ ដូច្នេះត្រូវបញ្ជូនទៅកន្លែងដែលភាគីបានជូនដំណឹងនោះ។ ម្យ៉ាងទៀត ទោះបីជាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការច្បាស់លាស់នៅក្នុងប្រទេសកម្ពុជា ឬមានការជូនដំណឹងអំពីកន្លែងដែលត្រូវបញ្ជូននោះ ក៏អាចធ្វើការបញ្ជូននៅកន្លែងដែលបានជួបប្រទះជននោះបានដែរ ប្រសិនបើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូនទេ[9]។

### គ.៤. ការបញ្ជូនដោយបង្គ្រប់កិច្ច

ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូននៅកន្លែងដែលត្រូវបញ្ជូននោះទេ មន្ត្រីទទួលបន្ទុកការបញ្ជូនអាចប្រគល់ឯកសារទៅឱ្យអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន[10]។ អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារគឺជាអ្នកយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន ឬយល់ពីអត្ថន័យនៃឯកសារដែលបានទទួល និងមានសមត្ថភាពអាចយកឯកសារនោះ ទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូនបាន។

### គ.៥. ការបញ្ជូនដោយទុកចោល

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារ(ការបញ្ជូនដោយបង្គ្រប់កិច្ច) មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ឯកសារនោះអាចទុកចោលនៅទីកន្លែងដែលត្រូវបញ្ជូននោះបាន ដោយមានអានុភាពដូចជាការបញ្ជូនដែរ[11]។ ឧទាហរណ៍ៈ អាជ្ញាសាលាបានបញ្ជូនដីការបស់តុលាការ ទៅឱ្យលោក ក ដែលជាដើមចោទ ពេលអាជ្ញាសាលាយកឯកសារនោះទៅដល់ផ្ទះលោក ក បែរជាបានជួបកញ្ញា ខ ដែលជាអ្នកបម្រើរបស់លោក ក ទៅវិញ។ នៅពេលនោះអាជ្ញាសាលាក៏បានប្រគល់ឯកសារនោះ ឱ្យទៅកញ្ញា ខ ដើម្បីទុកឱ្យលោក ក តែកញ្ញា ខ បានបដិសេធមិនព្រមទទួល ដោយសំអាងថាខ្លួនជាអ្នកបម្រើមិនហ៊ានទទួលឡើយ។ ចំពោះការសំអាងបែបនេះគឺមិនមែនជាមូលហេតុត្រឹមត្រូវនោះឡើយ ដូច្នេះអាជ្ញាសាលាត្រូវទុកឯកសារនៅទីនោះ ដោយធ្វើនៅចំពោះមុខកញ្ញា ខ នោះតែម្តង។

---

[9] មាត្រា២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[10] មាត្រា២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីដដែល

[11] មាត្រា២៥២ កថាខណ្ឌទី២ នៃក្រមនីតិវិធីដដែល

### ក.៦. ការបញ្ជូនដែលត្រូវធ្វើនៅបរទេស

ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស គឺនៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូន មានទីលំនៅនៅបទេស ហើយពុំមានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីបែបនេះតុលាការត្រូវអនុវត្តតាម ពីរ វិធី[12] ដើម្បីធ្វើការបញ្ជូន។ វិធីទី១ ក្នុងករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស ត្រូវធ្វើការបញ្ជូនដោយប្រគល់ឱ្យក្រសួង ឬស្ថាប័ន ដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ដូចជា ក្រសួងការបរទេស ឬស្ថានកុងស៊ុល ជាអាទិ៍។ វិធីទី២ ក្នុងករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរ តែរស់នៅបរទេស(អនិកជនខ្មែរ) ត្រូវតែបញ្ជូនដោយប្រគល់ឱ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះ ជាអ្នកអនុវត្តការបញ្ជូន។

មុននឹងបញ្ជូន តុលាការត្រូវធ្វើការពិនិត្យមើល អនុសញ្ញា ឬសន្ធិសញ្ញារវាងប្រទេសនោះ និងប្រទេសកម្ពុជា ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ព្រោះមានករណីខ្លះក្នុងបទដ្ឋានគតិយុត្តទាំងនោះ មានកំណត់ពីរបៀបនៃការបញ្ជូន។

### ក.៧. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

#### ក.៧.១. លក្ខខណ្ឌ

ការបញ្ជូនតាមការផ្សាយជាសាធារណៈ គឺជារបបមួយដែលជាចាំបាច់ ដើម្បីឱ្យដើមចោទអាចធ្វើបណ្ដឹងបាន ទោះបីជាមិនដឹងលំនៅឋានរបស់ចុងចម្លើយ ជាអាទិ៍ ហើយទោះបីមិនធ្វើការបញ្ជូនទៅតាមនីតិវិធីធម្មតាក៏ដោយ។ ប៉ុន្តែ ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយគោរពតាមរបៀបបញ្ជូនតាមការផ្សាយជាសាធារណៈ ហេតុនេះហើយ ដែលជាក់ស្ដែងគឺមានការលំបាកណាស់ដែលរំពឹងថា ជនដែលត្រូវទទួលការបញ្ជូននោះបានដឹងអំពីការបញ្ជូននោះ។ ដូច្នេះហើយប្រព័ន្ធនេះវាមានគ្រោះថ្នាក់បន្តិច ប្រសិនបើដើមចោទបានប្រើប្រព័ន្ធនេះដើម្បីធ្វើឱ្យការជម្រះក្ដីនោះលម្អៀងទៅរកខ្លួន នៅពេលដែលចុងចម្លើយមិនបានដឹង។ ដូចនេះ ដើម្បីការពារកុំឱ្យមានអំពើខិលខូចនេះកើតមានឡើង តុលាការត្រូវធ្វើការពិនិត្យលក្ខខណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈនេះឱ្យបានត្រឹមត្រូវ។

ការបញ្ជូនតាមការផ្សាយជាសាធារណៈ អាចធ្វើឡើងទាល់តែមានពាក្យសុំរបស់ភាគីដែលសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និងទាល់តែមានការយល់ព្រមអនុញ្ញាតពីតុលាការផងដែរ។ ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវតែគោរពនូវលក្ខខណ្ឌដូចខាងក្រោម៖

- ទោះបីបានខិតខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬកន្លែងផ្សេងទៀតដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញ។

[12] មាត្រា២៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ទោះបីបានដឹងពីទីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ប៉ុន្តែការបញ្ជូនមិនអាចធ្វើបាន ទោះជាព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ។

- មិនអាចធ្វើការបញ្ជូនទៅបរទេស ដោយការប្រគល់កិច្ចការបញ្ជូន ឬត្រូវបានទទួលស្គាល់ថាគ្មានលទ្ធភាពក្នុងករណីដែលត្រូវធ្វើការបញ្ជូននៅបរទេស។

- និងក្នុងករណីដែលតុលាការមិនបានទទួលលិខិតបញ្ជាក់ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេស ក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីពេលបញ្ជូន។

ចំពោះលក្ខខណ្ឌទាំងអស់នេះ ឱ្យតែមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដែលបានរៀបរាប់ខាងលើនេះ គឺអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។

ប៉ុន្តែក្នុងករណីដែលតុលាការយល់ឃើញថាមានភាពចាំបាច់ ដើម្បីជៀសវាងនូវការយឺតយ៉ាវក្នុងដំណើរការនីតិវិធី តុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ ទោះជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។

ក្នុងករណីដែលមិនអាចបញ្ជូនបានតាមការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល ក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យមួយ(តាមទូរស័ព្ទ ឬបិទនៅលំនៅឋាន ឬទីសំណាក់របស់អ្នកដែលត្រូវទទួលការបញ្ជូន ជាអាទិ៍) អំពីហេតុដែលនាំឱ្យធ្វើការបញ្ជូនជាសាធារណៈទៅភាគីដែលត្រូវទទួលការបញ្ជូននោះ។

ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពីលើកទី ២ ទៅ ហើយចំពោះភាគីដដែល តុលាការត្រូវធ្វើដោយឆន្ទានុសិទ្ធិរបស់តុលាការ លើកលែងករណីដែលត្រូវបញ្ជូនទៅជនដែលនៅបរទេស ត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ[13]។

### ក.៧.២. របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការថាក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលត្រូវបញ្ជូន និងអាចប្រគល់ឯកសារនោះទៅជនដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បាន។ ប៉ុន្តែចំពោះការបញ្ជូនដីកាកោះ តាមការផ្សាយជាសាធារណៈវិញ ត្រូវបិទដីកាកោះនោះនៅកន្លែងសម្រាប់បិទប្រកាស។

នៅក្នុងករណីដែលធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ មិនអាចបញ្ជូនតាមការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល ការបិទផ្សាយដែលកំណត់ក្នុងករណីខាងលើនេះ អាចធ្វើបាននៅកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ ក្រៅពីកន្លែងដែលបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ។

[13] មាត្រា២៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

តុលាការអាចចុះនៅក្នុងរាជកិច្ច ឬក្នុងសារព័ត៌មាន ផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីតុលាការអាចជូនដំណឹងថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ ជំនួសការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬក្នុងសារព័ត៌មាន[14]។

**ក.៧.៣. អានុភាពនៃការបញ្ជូនតាមផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈ នឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ២ សប្តាហ៍បានកន្លងហួស ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាស តាមរបៀបការបញ្ជូនតាមការផ្សាយជាសាធារណៈខាងលើ ប៉ុន្តែចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើការបញ្ជូនជាលើកទី ២ តាមការផ្សាយជាសាធារណៈចំពោះភាគីដដែល ដែលត្រូវធ្វើដោយឆន្ទានុសិទ្ធិនោះ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាសនោះ។

ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលត្រូវធ្វើនៅបរទេសវិញ នឹងត្រូវមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦ សប្តាហ៍ បន្ទាប់ពីថ្ងៃបិទប្រកាស[15]។

**ខ. របាយការណ៍អំពីការបញ្ជូន**

មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ដែលបានធ្វើការបញ្ជូនរួចហើយ ត្រូវធ្វើរបាយការណ៍ស្តីពីការបញ្ជូននោះ ដាក់ជូនតុលាការដើម្បីធ្វើការពិនិត្យពីលទ្ធផលនៃការបញ្ជូននោះ។

របាយការណ៍នោះ ត្រូវបញ្ជាក់អំពីចំណុចដូចតទៅ៖

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន គឺមន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើការបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្លួននូវរឿងក្តីដែលខ្លួនទទួលបន្ទុកបញ្ជូននោះ ថាជារឿងរដ្ឋប្បវេណី ហើយឯកសារដែលខ្លួនធ្វើការបញ្ជូននោះ ជាប្រភេទឯកសារបែបណា ជាលិខិតជូនដំណឹង ដីកា សេចក្តីសម្រេចផ្សេងៗរបស់តុលាការ។

- ជនដែលត្រូវទទួលការបញ្ជូន មានដូចជា ដើមចោទ ចុងចម្លើយ សាក្សី ឬតតិយជនផ្សេងៗទៀត ដែលមានការយល់ដឹងសមរម្យ អាចទទួលនូវឯកសារដែលធ្វើការបញ្ជូននោះបាន។

- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន គឺត្រូវបញ្ជាក់នៅក្នុងរបាយការណ៍ថា ខ្លួនបានបញ្ជូនឯកសារទៅទីកន្លែងណា ដែលអាចជាលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន ហើយការបញ្ជូននោះ ធ្វើឡើងនៅវេលាម៉ោង ថ្ងៃ ខែ ឆ្នាំ ណា ជាដើម។

[14] មាត្រា២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[15] មាត្រា២៥៧ នៃក្រមនីតិវិធីដដែល

- វិធីបញ្ជូន គឺត្រូវបញ្ជាក់ថាការបញ្ជូននោះធ្វើឡើងក្រោមរូបភាព ជាការបញ្ជូននៅកន្លែងជួបប្រទះ ឬការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល។

- ចំណាត់ការនៃការបញ្ជូន ចំពោះជនដែលមិនចេះអក្សរ គឺជាគោលការណ៍នៃការបញ្ជូនដោយការប្រគល់នៅពេលដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារបញ្ជូននោះ នៅពេលប្រគល់ឱ្យជននោះ។

- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ គឺក្រោយពេលប្រគល់ឯកសារបញ្ជូន មន្ត្រីទទួលបន្ទុកការបញ្ជូន ត្រូវឱ្យជនដែលទទួលបន្ទុកការបញ្ជូនចុះហត្ថលេខា ឬផ្តិតមេដៃនៅលើរបាយការណ៍នោះ។

- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន នៅក្នុងករណីដែលជនត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់តាមការបញ្ជូនបង្គ្រប់កិច្ចមិនព្រមទទួលការបញ្ជូនទេ ក្នុងករណីនេះ មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវសរសេរបញ្ជាក់នៅក្នុងរបាយការណ៍នូវហេតុការណ៍ និងមូលហេតុនៃការមិនព្រមទទួលឯកសារនៃការបញ្ជូននោះរបស់អ្នកដែលត្រូវទទួលការបញ្ជូន។

- ហេតុការណ៍នៅក្នុងករណីដែលការបញ្ជូនបានធ្វើតាមការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវកត់ត្រានូវហេតុការណ៍ទាំងអស់ជុំវិញការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោលនៅក្នុងរបាយការណ៍របស់ខ្លួនដើម្បីដាក់ជូនតុលាការពិនិត្យ។

- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ក្រោយពីធ្វើការបញ្ជូនរួចហើយ មន្ត្រីទទួលបន្ទុកការបញ្ជូន ត្រូវធ្វើរបាយការណ៍របស់ខ្លួនដោយមានចុះហត្ថលេខានៅលើរបាយការណ៍នោះផងដែរ។

នៅក្នុងករណីដែលបានព្យាយាមបញ្ជូន តែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះ និងត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោមជូនទៅតុលាការ៖

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន
- ជនដែលត្រូវទទួលការបញ្ជូន
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន
- វិធីបញ្ជូន
- ហត្ថលេខារបស់អ្នកដែលត្រូវប្រតិបត្តិការបញ្ជូន[16]។

[16] មាត្រា២៥៤ នៃក្រមនីតិរដ្ឋប្បវេណីឆ្នាំ២០០៦

## ផ្នែកទី២ ៖ ការបញ្ជូនដំណឹងក្នុងរឿងព្រហ្មទណ្ឌ

នៅក្នុងនីតិវិធីព្រហ្មទណ្ឌ អាជ្ញាសាលាបំពេញនូវកិច្ចការមួយចំនួនដូចជា កិច្ចការដែលទាក់ទងនឹងការកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់ កិច្ចការកោះហៅជនជាប់ចោទ និងជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ ដីកាបង្គាប់ឱ្យចូលខ្លួន និងដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ។

### កថាខណ្ឌទី១ ៖ ការបញ្ជូនដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់

ដីកាសម្រេចកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់ គឺជាបញ្ជាដល់ជនជាប់ចោទឱ្យចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូង ដែលសម្រេចរឿងព្រហ្មទណ្ឌ[17]។

#### ក. ការប្រគល់ដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់ អាចត្រូវបានប្រគល់ដោយអាជ្ញាសាលា។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីប្រគល់ដីកានោះដល់ជនជាប់ចោទដោយផ្ទាល់ដៃ[18]។

ប្រសិនបើអាជ្ញាសាលាជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬនៅកន្លែងដទៃទៀត អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះដល់សាមីជននោះ។ អាជ្ញាសាលាត្រូវចារសេចក្ដីលើដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទផ្ទាល់ដៃ ដោយត្រូវចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ចំពោះជនជាប់ចោទត្រូវចុះហត្ថលេខានៅដើមដីកា ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅព្រះរាជអាជ្ញាវិញភ្លាម[19]។

ប្រសិនបើជនត្រូវចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់ជនទាំងឡាយណាជានីតិជនដែលមានវត្តមាននៅលំនៅឋាននោះ។ អាជ្ញាសាលាចុះសេចក្ដីលើដើមដីកាថា ចុងដីកាត្រូវបានប្រគល់ឱ្យបុគ្គលដែលមានវត្តមាននៅលំនៅឋាន។ អាជ្ញាសាលាត្រូវចុះនិទ្ទេសស្ដីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលចុងដីកា ត្រូវចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាត្រូវបង្វិលមកព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានេះក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់ជនជាប់ចោទ[20]។

អាជ្ញាសាលាប្រគល់ចុងដីកា ឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង នៅក្នុងករណីដូចតទៅ[21]៖

- ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់

[17] មាត្រា៤៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[18] មាត្រា៤៥៩ នៃក្រមនីតិវិធីដដែល

[19] មាត្រា៤៦០ នៃក្រមនីតិវិធីដដែល

[20] មាត្រា៤៦១ នៃក្រមនីតិវិធីដដែល

[21] មាត្រា៤៦២ នៃក្រមនីតិវិធីដដែល

- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ

- គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុង លំនៅឋានរបស់ជនជាប់ចោទយល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកា អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលចុងដីកា ចុះហត្ថលេខារបស់ខ្លួននៅលើដើមដីកា ហើយដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម ចំពោះបុគ្គលដែលទទួលដីកា ត្រូវសន្យាថានឹងប្រគល់ដីកានោះក្នុងរយៈពេលខ្លីបំផុតឱ្យជនជាប់ចោទ។

### ខ. រយៈពេលដែលត្រូវកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់

រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនរឿងទៅជម្រះផ្ទាល់ ឱ្យជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ ត្រូវបានកំណត់ដូចតទៅ[22]៖

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង។
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ។
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងដទៃផ្សេងទៀត។

## កថាខណ្ឌទី២ ៖ ការបញ្ជូនដីកាកោះហៅជនជាប់ចោទ និងជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ

### ក. ការប្រគល់ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ

ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ គឺត្រូវបានប្រគល់ឱ្យជនជាប់ចោទដោយអាជ្ញាសាលា។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកាកោះហៅជនជាប់ចោទដោយផ្ទាល់ដៃ។

ប្រសិនបើអាជ្ញាសាលាជួបប្រទះជនជាប់ចោទនៅលំនៅឋាន ឬនៅកន្លែងដ៏ទៃទៀត អាជ្ញាសាលាប្រគល់ចុងដីកាកោះហៅជនជាប់ចោទនោះ។ អាជ្ញាសាលាចារនៅលើដើមដីកាកោះហៅថា ចុងដីកាត្រូវបានប្រគល់ឱ្យដល់ជាប់ចោទដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ។ ជនជាប់ចោទចុះហត្ថលេខាលើដើមដីកា ហើយដើមដីកាកោះហៅ ត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម។

ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋាន អាជ្ញាសាលាប្រគល់ចុងដីកាកោះឱ្យជនទាំងឡាយជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាចារលើដើមដីកាកោះថា ចុងដីកាកោះត្រូវបាន

[22] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ប្រគល់ឱ្យដល់បុគ្គលដែលមានវត្តមាននៅលំនៅឋាន។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកានោះ។ ដើមដីកាកោះនេះត្រូវបង្វិលជូនទៅព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលដីកាកោះនោះត្រូវសន្យាថា នឹងប្រគល់ដីកាកោះនោះដល់ជនជាប់ចោទក្នុងរយៈពេលខ្លីបំផុត។

អាជ្ញាសាលាប្រគល់ចុងដីកា ឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងណាមួយ ក្នុងករណីដូចតទៅ៖

- ជនជាប់ចោទមិនព្រមទទួលដីកាកោះ
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ
- គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ យល់ព្រមទទួលដីកាកោះទេ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកា អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា។ បុគ្គលដែលទទួលចុងដីកា ចុះហត្ថលេខារបស់ខ្លួននៅលើដើមដីកា ហើយដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម ចំពោះបុគ្គលដែលទទួលដីកា ត្រូវសន្យាថានឹងប្រគល់ដីកានោះក្នុងរយៈពេលខ្លីបំផុតឱ្យជនជាប់ចោទ។

### ខ. ការប្រគល់ដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ

ជនក្រៅពីជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ក្នុងករណីនេះ ដីកាកោះហៅជនទាំងនេះឱ្យចូលរួមសវនាការ ត្រូវអនុវត្តដូចនឹងនីតិវិធីនៃការកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការដោយអាជ្ញាសាលាផងដែរ។

### គ. រយៈពេលកោះហៅចូលរួមសវនាការ

រយៈពេលរវាងការប្រគល់ដីកាកោះហៅ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវបានកំណត់ដូចតទៅ៖

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង។
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ។
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងដទៃផ្សេងទៀត។

ប៉ុន្តែក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយរវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ។

## កថាខណ្ឌទី៣ ៖ ការបញ្ជូនដីកាបង្គាប់ឱ្យចូលខ្លួន និងការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ

### ក. ការបញ្ជូនដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព[23]។

ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ឬដោយភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។

បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរវិញ។

មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន[24]។

### ខ. ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ

ក្រោយពីតុលាការចេញសេចក្ដីសម្រេចរួចមក សេចក្ដីសម្រេចត្រូវធ្វើការជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធតាមរយៈដីកាឱ្យដំណឹង។

ដីកាឱ្យដំណឹង គឺជាលិខិតដែលឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់តម្រូវឱ្យជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធបានទទួលដំណឹងអំពីសេចក្ដីសម្រេចនោះ។

ដីកាឱ្យដំណឹង ត្រូវធ្វើតាមគំនិតផ្ដើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា ឬរបស់ភាគី ហើយការជូនដំណឹងអាចត្រូវបានធ្វើផងដែរ ដោយអាជ្ញាសាលា។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីជូនដំណឹងដល់បុគ្គលពាក់ព័ន្ធអំពីសេចក្ដីសម្រេចរបស់តុលាការ។

លិខិតចម្លងនៃសេចក្ដីសម្រេច ដែលត្រូវជូនដំណឹងដោយអាជ្ញាសាលា ត្រូវភ្ជាប់ទៅនឹងដីកាឱ្យដំណឹងអំពីដីកាសម្រេចរបស់តុលាការ។

### គ. ការប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចជូនដល់ភាគីពាក់ព័ន្ធ

ប្រសិនបើអាជ្ញាសាលាជួបប្រទះភាគីពាក់ព័ន្ធនៅក្នុងលំនៅឋាន ឬនៅកន្លែងដទៃទៀត អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចជូនដល់ភាគីពាក់ព័ន្ធ។

[23] មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[24] មាត្រា១៨៨ នៃក្រមនីតិវិធីដដែល

អាជ្ញាសាលាត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងនៃសេចក្ដីសម្រេចបានប្រគល់ជូនដល់ភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្ដីសម្រេចដើម។ សេចក្ដីសម្រេចដើមនេះ ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់។

ប្រសិនបើភាគីដែលពាក់ព័ន្ធអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន។

អាជ្ញាសាលាត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងនៃសេចក្ដីសម្រេចត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលា ត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេច។ ចំពោះបុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើម ហើយសេចក្ដីសម្រេចដើមនេះ ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ រីឯបុគ្គលដែលទទួលលិខិតចម្លងនៃសេចក្ដីសម្រេច ត្រូវសន្យាថានឹងប្រគល់ដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។

អាជ្ញាសាលាប្រគល់លិខិតនៃសេចក្ដីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬចៅសង្កាត់រងណាមួយ ក្នុងករណីដូចតទៅ៖

- ភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្ដីសម្រេច
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ
- គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធ យល់ព្រមទទួលសេចក្ដីសម្រេចនោះទេ។

អាជ្ញាសាលាត្រូវចុះនិទ្ទេសទៅលើសេចក្ដីសម្រេចដើម អំពីអត្តសញ្ញាណ និងឋានៈនៃបុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្ដីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតចម្លងត្រូវចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើម ហើយសេចក្ដីសម្រេចដើមនេះ ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ រីឯបុគ្គលដែលទទួលលិខិតចម្លងនៃសេចក្ដីសម្រេច ត្រូវសន្យាថានឹងប្រគល់ដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។

# ជំពូកទី២

# ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

សេចក្តីសម្រេចរបស់តុលាការទាមទារឱ្យមាននូវការអនុវត្ត ហើយអ្នកដែលទទួលបន្ទុកអនុវត្តនោះ គឺអាជ្ញាសាលា។ មានន័យថា អាជ្ញាសាលាជា**ស្ថាប័នអនុវត្តសេចក្តីសម្រេចរបស់តុលាការ**(ផ្នែកទី១) ឬជា**ជំនួយឱ្យតុលាការអនុវត្ត**(ផ្នែកទី២)។

## ផ្នែកទី ១ ៖ ស្ថាប័នអនុវត្តសេចក្តីសម្រេចរបស់តុលាការ

បន្ទាប់ពីតុលាការចេញសេចក្តីសម្រេចដែលទាក់ទងនឹងរឿងទាមទារចលនវត្ថុ ហើយដើម្បីអនុវត្តសេចក្តីសម្រេចនេះបាន ភាគីដែលជាម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំទៅកាន់អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីចុះអនុវត្ត។ នៅក្នុងករណីនេះ អាជ្ញាសាលាមិនមែនជាជំនួយឱ្យស្ថាប័នតុលាការទេ តែគឺជាស្ថាប័នអនុវត្ត គឺសម្រាប់ករណីចលនវត្ថុតែប៉ុណ្ណោះ។

ក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានតួនាទីត្រូវបំពេញការងារមួយចំនួនដែលទាក់ទងនឹងចលនវត្ថុតាមការស្នើសុំរបស់ភាគី លើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ។

### កថាខណ្ឌទី១ ៖ តួនាទីមុនពេលចាប់ផ្តើមការរឹបអូសចលនវត្ថុ

#### ក. នីតិវិធីដាក់ពាក្យសុំ

ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង នៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ[25]។

ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងពាក្យសុំនេះ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត[26]៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្តីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់

[25] មាត្រា៣៨៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[26] មាត្រា៣៨៥ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីដដែល

- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ក្រៅពីចំណុចខាងលើ យើងត្រូវសរសេរបញ្ជាក់អំពីទីកន្លែងដែលចលនវត្ថុនោះស្ថិតនៅ[27] ព្រោះក្នុងករណីអនុវត្តចំពោះចលនវត្ថុនេះ ខុសពីករណីអនុវត្តចំពោះអចលនវត្ថុ ដោយពុំចាំបាច់កំណត់ច្បាស់លាស់ចំពោះចលនវត្ថុដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលដាក់ពាក្យសុំនោះឡើយ។ មានន័យថា ក្នុងពាក្យសុំនេះគ្រាន់តែសរសេរថារឹបអូសចលនវត្ថុដែលមាននៅកន្លែងនេះ ឬនៅកន្លែងនោះតែប៉ុណ្ណោះ គឺចលនវត្ថុច្រើនប្រភេទដែលមាននៅកន្លែងនោះ គឺជាកម្មវត្ថុនៃការរឹបអូស។ ចំណុចនេះខុសពីពាក្យសុំការអនុវត្តលើអចលវត្ថុ ឬសិទ្ធិលើបំណុលផ្សេងទៀត ដោយសារតែមានការលំបាកក្នុងការសរសេរបញ្ជាក់លម្អិតនូវវត្ថុនីមួយៗដែលមាននោះ។ ហេតុនេះហើយ ការកំណត់លម្អិតស្តីពីចលនវត្ថុដែលអាចរឹបអូសបាននោះ ត្រូវប្រគល់ជូនអាជ្ញាសាលាសម្រេចពេលទៅដល់កន្លែងដែលត្រូវធ្វើការរឹបអូសនោះ។

ចំពោះលក្ខខណ្ឌនៃការដាក់ពាក្យសុំដែលបានកំណត់ខាងលើនេះ គឺត្រូវតែធ្វើការបង់សោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី ដែលមានដូចជា[28]៖

- ពន្ធដាក់ពាក្យសុំ គឺក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០(មួយម៉ឺន) រៀល ទៅតុលាការ រីឯក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង។

- សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ គឺម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធនូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ។

- សោហ៊ុយភាគី គឺជាសោហ៊ុយដែលតុលាការទទួលស្គាល់ថាចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដែលក្រៅពីសោហ៊ុយដែលបានកំណត់ពីខាងលើ។

ក្នុងករណីខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំពុំបានគោរពនូវលក្ខខណ្ឌនៃការបង្គាប់ឱ្យបង់សោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធីដែលច្បាប់បានកំណត់នោះទេ ពាក្យសុំនោះនឹងត្រូវបានលើកចោល។

[27] មាត្រា៣៨៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[28] មាត្រា៣៧១ នៃក្រមនីតិវិធីដដែល

## ខ. តួនាទីមុនពេលចាប់ផ្ដើមរឹបអូសចលនវត្ថុ

ជាគោលការណ៍ ដែលហៅថាចលនវត្ថុ គឺវត្ថុដែលអាចយកទៅគ្រប់គ្រងបាន។ រីឯផលធម្មជាតិមុននឹងបំបែកពីដីនោះ មិនមែនជាចលនវត្ថុទេ ប៉ុន្តែផលដែលបានទទួលពិតប្រាកដក្នុងអំឡុងពេល ១ ខែនោះ គឺជាទ្រព្យដែលនឹងក្លាយជាចលនវត្ថុក្នុងអំឡុងពេល ១ ខែ[29] ។

មុននឹងចាប់ផ្ដើមរឹបអូសចលនវត្ថុ អាជ្ញាសាលាត្រូវជូនលិខិតអនុវត្ត និងឯកសារផ្សេងៗទៅកូនបំណុលនៃការអនុវត្តជាមុន។

ក្នុងករណីដែលធ្វើការអនុវត្តដោយបង្ខំដោយយកសាលក្រមស្ថាពរ ឬសាលដីកាស្ថាពរ ធ្វើជាលិខិតអនុវត្តសាលក្រម ឬសាលដីកានោះ ត្រូវបានបញ្ជូនទៅឱ្យភាគីរួចទៅហើយ ដូចជាក្នុងករណីការបញ្ជូនលិខិតសាលក្រម ហេតុដូច្នេះនៅពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ ពុំចាំបាច់បញ្ជូនសារជាថ្មីទៀតទេ។

ការបញ្ជូនខាងលើនេះ ចាំបាច់ត្រូវធ្វើជាមុន ប៉ុន្តែចំពោះពេលវេលាច្បាស់លាស់ដែលត្រូវបញ្ជូនវិញ គឺខុសគ្នាទៅតាមប្រភេទនៃការអនុវត្ត ក្នុងការអនុវត្តចំពោះចលនវត្ថុ ឬការអនុវត្តឱ្យប្រគល់ ឬឱ្យចុះចេញដោយអាជ្ញាសាលា គ្រាន់តែបញ្ជូននៅពេលជាមួយគ្នានូវការចាប់ផ្ដើមការអនុវត្តនៅទីកន្លែងនោះបាន។

ចលនវត្ថុក្នុងន័យនេះ មានរួមបញ្ចូលទាំងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចទទួលបានផលនៅក្នុងអំឡុងពេល ១ ខែ[30]។

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬអ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬលក្ខណៈសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍បើជននោះទាមទារ។

ប្រសិនបើបានជួបប្រទះកូនបំណុលនៃការអនុវត្ត នៅកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះ សងបំណុលដោយស្ម័គ្រចិត្តនៅមុនពេលចាប់ផ្ដើមរឹបអូស។ ជាទូទៅម្ចាស់បំណុលនៃការអនុវត្តនេះ ច្រើនបានទទួលប្រាក់ដែលជាផលនៃការរឹបអូសចលនវត្ថុនេះបន្តិចបន្តួចតែប៉ុណ្ណោះ ហើយមិនស្របចិត្តទេ។ ក៏ប៉ុន្តែការរឹបអូសចលនវត្ថុនេះ គឺជាវិធីមួយដែលអាចប្រើដើម្បីបង្ខំខាងផ្លូវចិត្តកូនបំណុលនៃការអនុវត្តនោះ ហើយដាស់តឿនឱ្យសងបំណុលនោះបាន។ ហេតុនេះហើយ ការឱ្យអាជ្ញាសាលាដាស់តឿនទាមទារសំណងនេះ ជាការសមរម្យមួយដែរ។

[29] មាត្រា៣៨៤ កថាខណ្ឌទី៤ នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦

[30] មាត្រា៣៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីដដែល

ក្នុងករណីអនុវត្តចំពោះចលនវត្ថុ អាជ្ញាសាលាអាចទទួលសំណងនៃបំណុល និងសំណងនៃសោហ៊ុយសម្រាប់ការអនុវត្ត ដើម្បីម្ចាស់បំណុលនៃការអនុវត្តបាន។ ដោយសារអាជ្ញាសាលាជាស្ថាប័នអនុវត្តការរឹបអូសចលនវត្ថុ ហើយជួបផ្ទាល់នឹងកូនបំណុល ហេតុនេះហើយអាជ្ញាសាលានេះ អាចយល់ច្បាស់អំពីកម្មវត្ថុនៃសិទ្ធិទាមទារ ចំពោះកូនបំណុលនៃការអនុវត្ត។ ដូច្នេះហើយអាជ្ញាសាលា អាចត្រូវបានផ្តល់សិទ្ធិក្នុងការទទួលយកសំណងនេះបាន។ ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត មានចិត្តសងបំណុល អាចធ្វើឱ្យនីតិវិធីនៃការអនុវត្តនោះមានដំណើរការល្អ ហើយអាចបំបាត់នូវអ្វីៗដែលឥតប្រយោជន៍ក្នុងការអនុវត្តនោះបាន។

## កថាខណ្ឌទី២ ៖ តួនាទីនាពេលរឹបអូសចលនវត្ថុ

### ក. ការរឹបអូសចលនវត្ថុ

#### ក.១. ចលនវត្ថុកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត

ក្នុងករណីធ្វើការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវធ្វើដោយការកាន់កាប់ចលនវត្ថុនោះ។ ជាគោលការណ៍ ការរឹបអូសចលនវត្ថុ គឺត្រូវធ្វើតែចំពោះចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលតែប៉ុណ្ណោះ។ ក៏ប៉ុន្តែកម្មសិទ្ធិនៃចលនវត្ថុ មានការលំបាកនឹងដឹងណាស់តាមការមើលពីខាងក្រៅ ម្យ៉ាងទៀតចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តនោះ ភាគច្រើនជាកម្មសិទ្ធិរបស់កូនបំណុលនោះ។ ហេតុនេះហើយ បានជាចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល អាចត្រូវរឹបអូសបានទាំងអស់។ ចំពោះករណីដែលអ្នកផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត មានកម្មសិទ្ធិលើចលនវត្ថុដែលត្រូវរឹបអូសនោះ ម្ចាស់កម្មសិទ្ធិត្រូវប្តឹងតវ៉ាក្នុងឋានៈជាតតិយជន ដើម្បីការពារវត្ថុរបស់ខ្លួន។ ការកាន់កាប់ក្នុងន័យនេះសំដៅលើការកាន់កាប់ដោយផ្ទាល់ ហើយមិនមែនក្នុងន័យដោយប្រយោលឡើយ។

នៅពេលធ្វើការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយអាចធ្វើការឆែកឆេររកចលនវត្ថុដែលអាចរឹបអូសបាន។ ក្នុងករណីនេះ បើមានភាពចាំបាច់អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទ ទូដែក និងប្រអប់ផ្សេងទៀតបាន។ ចំពោះការអនុវត្តលើចលនវត្ថុ អាជ្ញាសាលាមានតួនាទីសម្រេចនូវចលនវត្ថុដែលត្រូវរឹបអូសនៅទីកន្លែងកំណត់ច្បាស់លាស់នោះ ក៏ប៉ុន្តែគួរតែរឹបអូសចលនវត្ថុណាដែលមិនសូវមានឥទ្ធិពលដល់ជីវភាពរស់នៅ និងវត្ថុដែលស្រួលដាក់លក់ឡាយឡុង ដើម្បីប្តូរជាលុយផង ជាការប្រសើរ។

នៅពេលធ្វើការជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ក្នុងលក្ខខណ្ឌពុំធ្វើឱ្យមានការខូចខាត ដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត។ ការរឹបអូសចលនវត្ថុត្រូវធ្វើឡើងតាមរយៈការកាន់កាប់ចលនវត្ថុដែលបានរឹបអូសនោះ ដោយ

អាជ្ញាសាលា។ ជាគោលការណ៍ មន្ត្រីអនុវត្តសាលក្រមនោះជាអ្នកទទួលខុសត្រូវកាន់កាប់ចលនវត្ថុនោះ។ ដូច្នេះហើយការរឹបអូសចលនវត្ថុដូចជា លុយ ឬគ្រឿងអលង្ការជាដើម ដែលជាវត្ថុមានតម្លៃ ហើយស្រួលដឹកជញ្ជូនផងនោះ តាមធម្មតាអាជ្ញាសាលាត្រូវរក្សាទុកវត្ថុទាំងនោះដោយខ្លួនឯង។ ក៏ប៉ុន្តែចំពោះចលនវត្ថុដែលមានការពិបាក ឬអស់សោហ៊ុយច្រើនក្នុងការដឹកជញ្ជូន ឬក្នុងការរក្សាទុកនោះ អាជ្ញាសាលាអាចសម្រួលដោយប្រគល់ឱ្យកូនបំណុលនៃការអនុវត្តដែលបានកាន់កាប់រហូតដល់ថ្ងៃរឹបអូសនោះ រក្សាទុកតទៅទៀតបាន។

ក្នុងករណីនេះត្រូវមានផ្លាកបញ្ជាក់ឱ្យដឹងថាជាចលនវត្ថុដែលបានរឹបអូស ដោយវិធីបិទភ្ជិតលើចលនវត្ថុនោះជាដើម។ ក្នុងករណីដែលអាជ្ញាសាលាបានឱ្យកូនបំណុលនៃការអនុវត្ត ថែរក្សាគ្រប់គ្រងនូវចលនវត្ថុដែលបានរឹបអូស ប្រសិនបើឃើញថាសមរម្យ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តប្រើចលនវត្ថុនោះបាន។

ប្រសិនបើយល់ឃើញថាចាំបាច់ អាជ្ញាសាលាអាចរក្សាគ្រប់គ្រងដោយខ្លួនឯងវិញនូវចលនវត្ថុ ដែលបានឱ្យកូនបំណុលនៃការអនុវត្តរក្សាគ្រប់គ្រងខាងលើ ឬអាចលុបចោលនូវការអនុញ្ញាតដែលបានធ្វើ ក្នុងករណីដែលអាជ្ញាសាលាបានឱ្យកូនបំណុលនៃការអនុវត្តរក្សាគ្រប់គ្រងនូវចលនវត្ថុដែលបានរឹបអូសខាងលើនេះបាន[31]។

**ក.២. ចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត**

ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត គឺអនុវត្តដូចគ្នាផងដែរទៅនឹងការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត[32] លើកលែងតែករណីខាងក្រោមនេះដែលមិនអាចអនុវត្តបាន គឺករណីដែលអាជ្ញាសាលាចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយអាចធ្វើការឆែកឆេររកចលនវត្ថុដែលអាចរឹបអូសនោះបាន។

ការអនុវត្តខាងលើអាចធ្វើទៅបាន ក្នុងករណីដែលតតិយជននោះមិនបដិសេធអំពីការប្រគល់ចលនវត្ថុនោះ។ ផ្ទុយទៅវិញ ប្រសិនបើតតិយជនមិនយល់ព្រមប្រគល់ចលនវត្ថុនោះដើម្បីរឹបអូសទេ គឺមានតែយកសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុដែលកូនបំណុលនោះមាន មកប្រើក្នុងនីតិវិធីអនុវត្តសិទ្ធិលើបំណុល ដើម្បីរឹបអូសយកចលនវត្ថុនោះ ចំពោះករណីនេះត្រូវប្រគល់ឱ្យតុលាការអនុវត្តជាអ្នកចាត់ចែង។

**ក.៣. ចលនវត្ថុទូទៅដែលបានចុះបញ្ជី**

ការអនុវត្តដោយបង្ខំចំពោះរថយន្ត ឬទោចក្រយានយន្ត ត្រូវធ្វើតាមវិធីអនុវត្តចំពោះចលនវត្ថុ។ នៅក្នុងករណីដែលមានពាក្យសុំ ដែលកំណត់តែកន្លែង ពុំមានកំណត់កម្មវត្ថុនៃការអនុវត្តទេ អាជ្ញាសាលា អាចរឹបអូស

---

[31] មាត្រា៣៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[32] មាត្រា៣៨៦ នៃក្រមនីតិវិធីដដែល

យករថយន្តដែលនៅទីនោះបាន ហើយក៏អាចកំណត់រថយន្តដែលជាកម្មវត្ថុនៃការអនុវត្តនោះ នៅពេលដាក់ពាក្យសុំផងដែរ។

ប្រសិនបើរថយន្ត ឬទោចក្រយានយន្ត ដែលត្រូវបានរឹបអូសបានចុះបញ្ជីក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលក្នុងសៀវភៅចុះបញ្ជីនោះ។ ការរឹបអូសខាងលើនេះ នឹងត្រូវមានអានុភាពនៅពេលបានសរសេរនូវហេតុការណ៍នៃការរឹបអូសចូលទៅក្នុងសៀវភៅចុះបញ្ជី។

ការរឹបអូសចំពោះចលនវត្ថុក្រៅពីវត្ថុ ឬទោចក្រយានយន្ត ដែលចាំបាច់ត្រូវចុះបញ្ជី ត្រូវអនុវត្តដូចគ្នាផងដែរ[33]។

### គ.៤. អានុភាពនៃការរឹបអូស

ការរឹបអូសមានអានុភាពទៅលើផលធម្មជាតិ ដែលកើតចេញពីចលនវត្ថុដែលត្រូវបានរឹបអូស[34]។ អានុភាពនៃការរឹបអូសមានទៅលើផលធម្មជាតិ ដែលបានមកពីចលនវត្ថុរឹបអូសនោះដែរ ទោះបីជាមិនបានធ្វើនីតិវិធីពិសេសក៏ដោយ។ ដោយសារតែអាជ្ញាសាលា ជាអ្នកគ្រប់គ្រងនូវចលនវត្ថុដែលរឹបអូសបាននោះ ហេតុនេះបានជាមិនត្រូវការនីតិវិធីពិសេសថែមទៀត ដើម្បីរឹបអូសផលនោះទេ។ ឧទាហរណ៍: ក្នុងករណីដែលបានរឹបអូសសត្វពាហនៈ ដែលជាសត្វគោ ដូច្នេះកូនគោគឺជាផលធម្មជាតិដែលកើតចេញពីចលនវត្ថុនោះ។

### ខ. ការរួមបញ្ចូលរឿងក្តី

ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការរឹបអូសរួចហើយ នៅទីកន្លែងរឹបអូសដដែលនោះ បើមានចលនវត្ថុដែលមិនទាន់បានរឹបអូសនៅឡើយ អាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុនោះ ហើយប្រសិនបើគ្មានចលនវត្ថុដែលត្រូវរឹបអូសបានទេនោះ អាជ្ញាសាលាត្រូវបញ្ជាក់ច្បាស់លាស់អំពីហេតុការណ៍នោះ ហើយត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលនវត្ថុថ្មីនោះ និងរឿងក្តីអនុវត្តចលនវត្ថុមុនជាមួយគ្នា។ អនុវត្តដូចគ្នាផងដែរចំពោះករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុទៅលើកូនបំណុលនៃការអនុវត្ត ដែលបានទទួលនូវការរឹបអូសជាបណ្តោះអាសន្ន នៅទីកន្លែងនៃការអនុវត្តដដែលនោះទេ។

បើរឿងក្តីអនុវត្តចំពោះចលនវត្ថុទាំងពីរ ត្រូវបានរួមបញ្ចូលគ្នាតាមកថាខណ្ឌខាងលើ ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីនាពេលក្រោយ ត្រូវចាត់ទុកថាការរឹបអូសក្នុងរឿងក្តីពីមុន នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីដែលធ្វើពេលក្រោយបាន មានអានុភាពជាការទាមទារចែកចំណែក។ បើម្ចាស់បំណុល

[33] មាត្រា៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[34] មាត្រា៣៨៩ នៃក្រមនីតិវិធីដដែល

នៃការអនុវត្តមុន បានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬនីតិវិធីដែលបានចាប់ផ្តើមដោយពាក្យសុំនោះត្រូវបានផ្អាក ឬត្រូវបានលុបចោលចលនវត្ថុដែលត្រូវរឹបអូសក្នុងរឿងក្តីមុននេះ ត្រូវចាត់ទុកថាបានរឹបអូសដើម្បីរឿងក្តីនៅពេលក្រោយ នៅពេលរួមបញ្ចូលរឿងក្តី។

បើរឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្ន និងរឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុ ត្រូវបានរួមបញ្ចូលគ្នាដូចករណីខាងលើនេះ ចលនវត្ថុដែលត្រូវបានអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថាបានរឹបអូសក្នុងរឿងក្តីនៃការអនុវត្ត ចំពោះចលនវត្ថុនៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ននេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក។ បើម្ចាស់បំណុលនៃការអនុវត្តបានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬនីតិវិធីដែលបានចាប់ផ្តើមដោយពាក្យសុំនោះ ត្រូវបានលុបចោលចលនវត្ថុដែលបានរឹបអូសក្នុងរឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុនេះ ត្រូវចាត់ទុកថាបានអនុវត្តរឹបអូសជាបណ្តោះអាសន្នក្នុងរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅពេលរួមបញ្ចូលរឿងក្តី។

នៅពេលដែលបានរួមបញ្ចូលរឿងក្តី អាជ្ញាសាលាត្រូវជូនដំណឹងអំពីហេតុការណ៍នោះទៅម្ចាស់បំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និងកូនបំណុលនៃការអនុវត្ត[35]។

### គ. ចលនវត្ថុដែលបានទទួលយកពីតតិយជន

អាជ្ញាសាលាអាចប្រគល់ចលនវត្ថុដែលអាចរឹបអូសបាននោះ ឱ្យកូនបំណុលនៃការអនុវត្តនោះរក្សាទុកបាន។ ក្នុងករណីរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដែលកាន់កាប់ដោយតតិយជនក៏ដោយ ក៏អាចឱ្យតតិយជននោះរក្សាចលនវត្ថុដែលរឹបអូសនោះបន្តទៅទៀតបាន។ ហេតុនេះហើយ បានជាមានបញ្ហាដែលអាចកើតឡើងដូចជា កូនបំណុលនៃការអនុវត្ត ឬតតិយជនដែលបានរក្សាទុកនូវចលនវត្ថុនោះ អាចចាត់ចែងលក់ ឬផ្ទេរឱ្យអ្នកផ្សេងទៀតកាន់កាប់ដោយចិត្តឯងបាន។ ដើម្បីការពារបញ្ហាដែលអាចកើតមានឡើងនេះ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះប្រគល់ចលនវត្ថុដែលបានរឹបអូសនោះទៅអាជ្ញាសាលាបានដោយដីកាសម្រេចតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។

ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តខាងលើ ត្រូវធ្វើក្នុងអំឡុងពេល ១ សប្តាហ៍ គិតពីថ្ងៃដែលបានដឹងថាចលនវត្ថុដែលបានរឹបអូសនោះកាន់កាប់ដោយតតិយជន។ ចំពោះដីកាសម្រេចអំពីពាក្យសុំខាងលើនេះអាចប្តឹងជំទាស់បាន។ ដីកាសម្រេចតាមពាក្យសុំខាងលើនេះ ពុំត្រូវអនុវត្តឡើយបើហួសអំឡុងពេល ២ សប្តាហ៍ចាប់គិតពីថ្ងៃដែលបានជូនដំណឹងទៅឱ្យអ្នកដាក់ពាក្យសុំ។ ដីកាសម្រេចតាមពាក្យសុំនេះអាចអនុវត្តបាន ទោះបីនៅមុនពេលបញ្ជូនដីកាសម្រេចនោះទៅឱ្យតតិយជនដែលកាន់កាប់ចលនវត្ថុដែលត្រូវបានរឹបអូសក៏ដោយ។

[35] មាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

សោហ៊ុយដែលចាំបាច់សម្រាប់ដីកាសម្រេច ដែលបង្គាប់ឱ្យតតិយជនប្រគល់ចលនវត្ថុ ដែលត្រូវរឹបអូសខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ចំពោះនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ[36]។

### ឃ. ការហាមឃាត់ និងការលុបចោលការរឹបអូស

#### ឃ.១. ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ

ការរឹបអូសចលនវត្ថុ មិនត្រូវធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលលើការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្តទេ។

ប្រសិនបើបានដឹងច្បាស់ថា ការរឹបអូសត្រូវធ្វើលើសកម្រិតដែលបានហាមឃាត់ខាងលើនេះ នៅក្រោយពេលដែលបានរឹបអូសរួចហើយ អាជ្ញាសាលាត្រូវរឹបអូសត្រឹមផ្នែកដែលត្រូវបានរឹបអូសហួសកម្រិតនោះ[37]។

#### ឃ.២. ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណថាគ្មានចំនួនសេសសល់

អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ។

អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីបានសងសិទ្ធិលើបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធីឡើយ[38]។

#### ឃ.៣. ការលុបចោលនូវការរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថាមិនអាចលក់បាន

អាជ្ញាសាលា អាចលុបចោលការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន ក្នុងលក្ខខណ្ឌដែលបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ក៏នៅតែមិនអាចលក់បាន ហើយប៉ាន់ប្រមាណឃើញថា នៅតែមិនអាចលក់បាននៅពេលអនាគត[39]។

## កថាខណ្ឌទី៣ ៖ តួនាទីក្រោយពេលរឹបអូសចលនវត្ថុ(ពេលលក់ចលនវត្ថុ)

### ក. វិធីលក់

ដើម្បីលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវលក់តាមវិធីឡាយឡុងដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រ។ ក្នុងចំណោមវិធីលក់ចលនវត្ថុ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីមួយ

[36] មាត្រា៣៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[37] មាត្រា៣៩១ នៃក្រមនីតិវិធីដដែល

[38] មាត្រា៣៩២ នៃក្រមនីតិវិធីដដែល

[39] មាត្រា៣៩៣ នៃក្រមនីតិវិធីដដែល

ដែលសមរម្យងាយស្រួលក្នុងការអនុវត្ត។ ប៉ុន្តែមានករណីដែលគួរធ្វើការលក់ឡាយឡុងដោយដាក់ស្រោមសំបុត្រ ដូចជា គ្រឿងម៉ាស៊ីនជាដើម ដែលជាចលនវត្ថុមានតម្លៃខ្ពស់ ហើយដែលអាចកំណត់តម្លៃអប្បរមា តាមការវាយតម្លៃរបស់អ្នកវាយតម្លៃ។

បើយល់ឃើញថាសមរម្យ ដោយគិតពិចារណាអំពីប្រភេទ និងចំនួននៃចលនវត្ថុ ជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ ក្រៅពីរបៀបលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រ ឬអាចឱ្យបុគ្គលផ្សេងក្រៅពីអាជ្ញាសាលា អនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ ដោយបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ។

អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវបានដាក់លក់ និងវិធីលក់ចលនវត្ថុនោះ ដោយចលនវត្ថុដែលរឹបអូសនោះលក់ឡាយឡុង ប្រសិនបើកូនបំណុលមានលុយដើម្បីយកទៅដេញថ្លៃ កូនបំណុលនោះត្រូវយកលុយនោះសងបំណុលសិន។

ចំពោះកូនបំណុលនៃការអនុវត្តដែលមិនបានសងបំណុលរហូតដល់ត្រូវគេរឹបអូស ហើយចាប់ផ្តើមដាក់ចលនវត្ថុដែលរឹបអូសនោះលក់ឡាយឡុង ប្រសិនបើកូនបំណុលមានលុយដើម្បីយកទៅដេញថ្លៃ កូនបំណុលនោះត្រូវយកលុយនោះសងសំណងសិន។

ប្រសិនបើអាជ្ញាសាលាអនុញ្ញាតឱ្យទិញ អ្នកទិញត្រូវបង់ថ្លៃភ្លាមៗ ក្នុងករណីនេះអ្នកទិញត្រូវបានហៅថា អ្នកស្នើសុំទិញក្នុងតម្លៃអប្បរមា ហើយអ្នកទិញនោះត្រូវបង់ប្រាក់កក់ដប់ភាគរយ នៃតម្លៃចលនវត្ថុដែលត្រូវបានដេញថ្លៃនោះ។

ប្រសិនបើចលនវត្ថុនោះត្រូវបានដាក់លក់ម្តងទៀត ដោយសារអ្នកទិញមិនបានបង់ថ្លៃ អ្នកសុំទិញមុននោះ មិនអាចធ្វើសំណើសុំទិញម្តងទៀតបានឡើយ ក្នុងករណីបានរឹបអូសចលនវត្ថុដែលមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះធ្វើការវាយតម្លៃចំពោះចលនវត្ថុនោះ[40]។

### ខ. ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់

ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យមានការរំខានដល់អ្នកដទៃទៀតក្នុងការធ្វើសំណើទិញ ឬបានឃុបឃិត ដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ ឬចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ ឬអាចដេញជននោះចេញពីកន្លែងលក់ ឬអាចមិនឱ្យស្នើសុំទិញបាន[41]។

[40] មាត្រា៣៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[41] មាត្រា៣៩៦ នៃក្រមនីតិវិធីដដែល

**គ. ការលក់នៅក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក**

ក្នុងករណីដែលមានការដាក់ឯកសារ ដូចខាងក្រោមនេះ៖

- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់បង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។

- ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬយល់ព្រមពន្យារពេលត្រូវសង នៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។

ប្រសិនបើបារម្ភថា តម្លៃលក់ចលនវត្ថុដែលត្រូវបានរឹបអូសនឹងចុះថោកខ្លាំង ឬត្រូវចំណាយសោហ៊ុយច្រើនមិនសមរម្យលំដាប់រក្សាទុកនូវចលនវត្ថុនោះ អាជ្ញាសាលាអាចដាក់ចលនវត្ថុដែលត្រូវរឹបអូសនោះលក់បាន។

បើចលនវត្ថុត្រូវបានរឹបអូសតាមករណីខាងលើនេះ អាជ្ញាសាលាត្រូវផ្ញើទុកប្រាក់ដែលបានមកពីការលក់នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ[42]។

**ឃ. ការចែកចំណែក**

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ៖

- ម្ចាស់បំណុលនៃការអនុវត្ត

- ម្ចាស់បំណុលនៃការទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ ចំពោះប្រាក់ដែលបានមកពីការលក់

- ម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលបានរឹបអូសប្រាក់ ចំពោះប្រាក់ដែលត្រូវបានរឹបអូស[43]។

ម្យ៉ាងវិញទៀត ចំពោះបុគ្គលដែលទទួលបានឯកសិទ្ធិ ឬមានសិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យចែកចំណែកបាន ដោយដាក់ឯកសារបញ្ជាក់អំពីសិទ្ធិនោះ។

ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានមកពីការលក់ ឬប្រាក់ដែលត្រូវបានរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែកចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់ដែលនៅសេសសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ។

ក្រៅពីករណីដែលបានកំណត់ដូចខាងលើនេះ បើបានទទួលប្រាក់ពីការលក់ ឬបានពីការរឹបអូសប្រាក់ អាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ២ សប្ដាហ៍ ជាថ្ងៃដែលត្រូវពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់

[42] មាត្រា៣៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[43] មាត្រា៣៩៨ នៃក្រមនីតិវិធីដដែល

ដែលបានមកពីការលក់ ឬប្រាក់ដែលត្រូវបានរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និងទីកន្លែងទៅម្ចាស់បំណុលនីមួយៗ។ បើម្ចាស់បំណុលនីមួយៗបានពិភាក្សាគ្នាដាច់ស្រេចហើយ អាជ្ញាសាលាត្រូវចែកចំណែកតាមការពិភាក្សានោះ។ ប្រសិនបើការពិភាក្សាគ្នាមិនបានលទ្ធផលល្អទេ អាជ្ញាសាលាត្រូវធ្វើកំណត់កាលបរិច្ឆេទដើម្បីធ្វើការបែងចែកចំណែក[44]។

ក្នុងករណីដែលមានការចែកចំណែកដូចខាងលើ ប្រសិនបើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវបានទទួលចំណែកនោះ មានមូលហេតុដូចបានកំណត់នៅក្នុងចំណុចខាងក្រោមនេះ អាជ្ញាសាលាត្រូវដាក់ប្រាក់ដែលស្មើនឹងចំណែកនោះ ផ្ញើទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ហើយត្រូវរាយការណ៍អំពីហេតុការណ៍នោះទៅសាលាដំបូងនោះ៖

- បើសិទ្ធិលើបំណុលនោះមានភ្ជាប់នូវលក្ខខណ្ឌបង្អង់ ឬកំណត់ពេលមិនពិតប្រាកដ
- បើសិទ្ធិលើបំណុលនោះ ជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន
- បើមានដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់ជាការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ
- បើបានដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ។

អាជ្ញាសាលាត្រូវផ្ញើទុកនូវទឹកប្រាក់ និងចំណែកចំពោះម្ចាស់បំណុលដែលមិនបានបង្ហាញខ្លួន ដើម្បីទទួលចំណែកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ[45]។

ប្រសិនបើបានទទួលលិខិតលុបចោលការរឹបអូស ដូចជា៖

- ឯកសារចម្លងយថាភូត នៃសេចក្ដីសម្រេចដែលលុបចោលលិខិតអនុវត្តក្រៅពីលិខិតយថាភូតនៃសេចក្ដីសម្រេចដែលលុបចោលការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន
- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ
- អនុសារសាលក្រមស្ថាពរ ឬអនុសារសាលដីកាស្ថាពរដែលប្រកាសថាការផ្សះផ្សា ឬការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព
- ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬឯកសារផ្សេងទៀតដែលបានបាត់បង់អានុភាពដោយសារការដកពាក្យបណ្ដឹង ឬមូលហេតុផ្សេងទៀត

[44] មាត្រា៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[45] មាត្រា៤០០ នៃក្រមនីតិវិធីដដែល

- ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី ដែលកំណត់ថាមិនអាចអនុវត្តដោយបង្ខំ ឬដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ

- ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ

- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និងការលុបចោលការចាត់ចែងការអនុវត្ត[46]។

ក្រោយពេលអ្នកទិញបង់ថ្លៃលក់ហើយ ដែលជាដំណាក់កាលមួយមិនអាចបដិសេធលទ្ធកម្មចលនវត្ថុដោយការបង់ថ្លៃលក់ ហេតុនេះហើយ មិនអាចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំបានទេ។ ក្នុងករណីនេះមិនអាចបែងចែកចំណែកដល់ម្ចាស់បំណុល ដែលមានមូលហេតុត្រូវលុបចោលនូវការអនុវត្តដោយបង្ខំនោះទេ ក៏ប៉ុន្តែប្រសិនបើម្ចាស់បំណុលផ្សេងទៀតដែលត្រូវទទួលចំណែកនោះ ក្រៅពីម្ចាស់បំណុលដែលមានមូលហេតុមិនអាចទទួលបានការបែងចែក អាជ្ញាសាលាត្រូវចាត់ចែងការចែកចំណែកនោះ។

ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់ ដូចជា៖

- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។

- ឯកសារដែលសរសេរថាម្ចាស់បំណុលទទួលសំណង ឬបានយល់ព្រមពន្យារពេលសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើតឡើង[47]។

ក្រោយពេលអ្នកទិញបង់ថ្លៃលក់ហើយមិនអាចបដិសេធលទ្ធកម្មចលនវត្ថុដោយការបង់ថ្លៃលក់ ហេតុនេះ អាជ្ញាសាលាត្រូវធ្វើការចែកចំណែកនៃការលក់នោះ។ ចំពោះការចែកចំណែក សិទ្ធិលើបំណុលដែលបានកំណត់ពេលពិតប្រាកដពុំទាន់មកដល់ ត្រូវចាត់ទុកថាកំណត់ពេលសងនោះបានចូលមកដល់ហើយ។

## ផ្នែកទី២ ៖ ជំនួយឱ្យតុលាការអនុវត្ត

ក្នុងនាមជាជំនួយឱ្យតុលាការអនុវត្ត អាជ្ញាសាលាត្រូវអនុវត្តតាមការចាត់តាំងរបស់តុលាការអនុវត្ត និងអនុវត្តដោយផ្ទាល់តាមការចាត់តាំងរបស់សាលាដំបូងក្នុងការចាត់ចែងរក្សាការពារ។

### កថាខណ្ឌទី ១ ៖ ការអនុវត្តតាមការចាត់តាំងរបស់តុលាការអនុវត្ត

ក្នុងករណីអនុវត្តតាមការចាត់តាំងរបស់តុលាការអនុវត្ត អាជ្ញាសាលាមានតួនាទីអនុវត្តទៅលើសិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗ ដូចជាអចលនវត្ថុ និងនាវា។

[46] មាត្រា៣៧០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[47] មាត្រា៣៧០ កថាខណ្ឌទី២ នៃក្រមនីតិវិធីដដែល

### ក. តួនាទីក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗទៀត

#### ក.១. អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និងតុលាការអនុវត្ត

សិទ្ធិលើបំណុល គឺជាសិទ្ធិទាមទាររបស់ម្ចាស់បំណុលទៅលើកូនបំណុលទី៣ នូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃបំណុលនោះ។ ក្នុងន័យនេះ កូនបំណុលទី៣ សំដៅលើកូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស។

ឧទាហរណ៍: ក្នុងករណី ក ជំពាក់ប្រាក់ ខ ចំនួន ៣០(សាមសិប) លានរៀល។ ក ជាកូនបំណុលមានប្រាក់នៅធនាគារ គ ដែលមានតម្លៃប្រហែល ៣៥(សាមសិបប្រាំ) លានរៀល។ នៅក្នុងនីតិវិធីនៃបណ្ដឹងទាមទារប្រាក់កម្ចីនេះ ត្រូវបានចំណាយពេលវេលាច្រើន ដោយម្ចាស់បំណុល ខ អាចនឹងបាត់បង់ប្រយោជន៍ ប្រសិនបើករណីដែល ក បានទៅធនាគារ ហើយបានដកប្រាក់បញ្ញើទាំងអស់ទៅចំណាយអស់។ ដូច្នេះដើម្បីការពារផលប្រយោជន៍របស់ខ្លួន ខ ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវគណនីធនាគាររបស់ ក ដើម្បីធានាការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល ខ នៅពេលដែលគាត់ឈ្នះក្ដី។ ដូច្នេះក្រោយពេលមានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវគណនីរបស់ ក ហើយ គឺ ក នឹងមិនអាចទៅដកប្រាក់របស់ខ្លួនបានទៀតនោះទេ។ ដោយនៅក្នុងករណីនេះ ធនាគារដែល ក បានផ្ញើប្រាក់នោះ គឺជាកូនបំណុលទី៣។

ការអនុវត្តចំពោះសិទ្ធិលើបំណុល សំដៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឱ្យសងជាប្រាក់ ឬប្រគល់ចលនវត្ថុ។ ជាគោលការណ៍ ការអនុវត្តចំពោះសិទ្ធិលើបំណុលអាចធ្វើបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប៉ុន្តែប្រសិនបើតតិយជនដែលកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តមិនព្រមប្រគល់វត្ថុនោះ ការអនុវត្តដោយបង្ខំត្រូវធ្វើ មិនមែនតាមការអនុវត្តចំពោះចលនវត្ថុទេ គឺតាមការអនុវត្តចំពោះសិទ្ធិលើបំណុល។

ក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល តុលាការអនុវត្តដែលមានសមត្ថកិច្ច គឺតុលាការដែលត្រូវបានកំណត់តាមលំនៅឋាន ជាអាទិ៍ របស់កូនបំណុលនៃការអនុវត្ត។ ប៉ុន្តែក្នុងករណីកូនបំណុលនៃការអនុវត្តគ្មានលំនៅឋាន ជាអាទិ៍ ដូចជាករណីដែលកូនបំណុលនៃការអនុវត្តនោះរស់នៅបរទេស ហើយដែលមិនមានលំនៅឋាននៅក្នុងប្រទេសកម្ពុជា នោះលំនៅឋាន ជាអាទិ៍ របស់កូនបំណុលទី៣ ត្រូវយកធ្វើជាមូលដ្ឋានដើម្បីកំណត់តុលាការដែលមានសមត្ថកិច្ច។ ក្នុងករណីដែលដីកាសម្រេចរឹបអូសបានចេញម្ដងទៀត ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស បើតុលាការអនុវត្តដែលបានចេញដីកាសម្រេចរឹបអូសនោះខុសគ្នា តុលាការអនុវត្តអាចផ្ទេររឿងក្ដីនោះ ទៅតុលាការអនុវត្តផ្សេងបាន[48]។

[48] មាត្រា៤០២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

## ក.២. ការអនុវត្តដីកាសម្រេចបង្គាប់ឱ្យលក់

ប្រសិនបើសិទ្ធិលើបំណុលត្រូវបានរឹបអូសមានលក្ខខណ្ឌ ឬមានកំណត់ពេល ឬមានការលំបាកក្នុងការប្រមូល ដោយសារភ្ជាប់នឹងតាវកាលិកតប ឬមានហេតុផ្សេងទៀត តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ ដោយវិធីដែលកំណត់ដោយតុលាការអនុវត្ត ហើយឱ្យយកប្រាក់ដែលបានមកពីការលក់នោះទៅឱ្យតុលាការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។

ក្នុងករណីខាងលើ បង្ហាញអំពីនីតិវិធីបង្គាប់ឱ្យលក់ ដែលជាវិធីប្តូរប្រាក់ជាពិសេស ក្នុងករណីដែលមានការលំបាកក្នុងការប្រមូលធម្មតាបាន ដោយសារមានមូលហេតុដូចជា សិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះមានលក្ខខណ្ឌ មានកំណត់ពេល ឬភ្ជាប់នឹងតាវកាលិកជាដើម។ នេះគឺជានីតិវិធីពិសេស ហេតុនេះហើយ ដើម្បីជ្រើសរើសយកនីតិវិធីនេះ ត្រូវសួរកូនបំណុលនៃការអនុវត្ត ប៉ុន្តែមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកូនបំណុល ដែលការអនុវត្តនៅបរទេស ឬមិនដឹងលំនៅឋានរបស់កូនបំណុលនោះ។

ប្រសិនបើយល់ឃើញថា ប្រាក់ដែលបានមកពីការលក់សិទ្ធិលើបំណុលដែលបានមកពីការរឹបអូសនោះក្រោយពីបានសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសងសោហ៊ុយសម្រាប់នីតិវិធី ហើយមិនសល់នោះទេ តុលាការអនុវត្តមិនអាចចេញដីកាសម្រេចខាងលើនេះបានឡើយ។ ចំពោះដីកាសម្រេចអំពីពាក្យសុំខាងលើនេះ អាចប្តឹងជំទាស់បាន។ ហើយដីកាសម្រេចនេះនឹងមានអានុភាពនៅពេលចូលជាស្ថាពរ។

ក្នុងករណីដែលចេញដីកាសម្រេច ដែលបានកំណត់ក្នុងករណីខាងលើ បើយល់ឃើញថាចាំបាច់តុលាការអនុវត្តអាចជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យធ្វើការវាយតម្លៃសិទ្ធិលើបំណុលបាន។

អាជ្ញាសាលាមិនអាចលក់សិទ្ធិលើបំណុលបានឡើយ ប្រសិនបើប្រាក់ដែលបានមកពីការលក់សិទ្ធិលើបំណុលនោះ ក្រោយពីបានសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលនៃការអនុវត្ត ព្រមទាំងសោហ៊ុយសម្រាប់នីតិវិធី ហើយមិនអាចសេសសល់ទេនោះ។

ចំពោះការលក់ដែលបានកំណត់ខាងលើ កូនបំណុលនៃការអនុវត្តមិនអាចធ្វើសំណើទិញបានឡើយ។

បើបានលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវជូនដំណឹងអំពីអនុប្បទានដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរ ចំពោះកូនបំណុលទី៣ ជំនួសកូនបំណុលនៃការអនុវត្ត។

បើបានបញ្ចប់ការលក់ខាងលើ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាពតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តនោះ តុលាការត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត

សម្រាប់អ្នកទិញ ដែលបានទទួលសិទ្ធិលើបំណុល ហើយផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ច លុបចោលនូវការចុះបញ្ជីដែលបានធ្វើតាមពាក្យសុំរបស់អ្នកទិញ[49]។

**ក.៣. ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ**

ម្ចាស់បំណុលដែលរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ អាចទាមទារឱ្យកូនបំណុលទី៣ ប្រគល់វត្ថុនោះទៅអាជ្ញាសាលា ដែលទទួលពាក្យសុំពីម្ចាស់បំណុលនៃការអនុវត្តបាន បើអំឡុងពេល ១ សប្តាហ៍បានកន្លងហួស ដោយគិតចាប់ពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត។ ក្នុងករណីដែលកូនបំណុលទី៣ កាន់កាប់ចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ហើយកូនបំណុលទី៣នេះប្រកែកមិនព្រមប្រគល់វត្ថុនោះទេ ការអនុវត្តដោយបង្ខំមិនអាចធ្វើតាមវិធីអនុវត្តចំពោះចលនវត្ថុទេ ពេលនោះនឹងត្រូវធ្វើតាមវិធីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុវិញ។ ក្នុងករណីនេះ ប្រហាក់ប្រហែលនឹងករណីរឹបអូសសិទ្ធិលើបំណុលជាប្រាក់ដែរ ម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យកូនបំណុលទី៣ ប្រគល់ចលនវត្ថុនោះ។

ពេលដែលទទួលការប្រគល់ចលនវត្ថុ អាជ្ញាសាលាត្រូវលក់វត្ថុនោះតាមវិធីលក់ចលនវត្ថុ ហើយត្រូវប្រគល់ប្រាក់ដែលបានមកពីការលក់ទៅតុលាការអនុវត្ត[50]។

**ក.៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត**

សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតមានន័យថា ជាសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីចលនវត្ថុ អចលនវត្ថុ នាវា និងសិទ្ធិលើបំណុល[51]។ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដូចជា សិទ្ធិជួល សិទ្ធិនិពន្ធ សិទ្ធិប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិជាសមាជិកនៃក្រុមហ៊ុន សិទ្ធិទាមទារឱ្យប្រគល់នាវា ឬអចលនវត្ថុជាដើម។ ប្រសិនបើគ្មានបញ្ញត្តិពិសេសទេ ការអនុវត្តចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតនោះ ត្រូវធ្វើតាមវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល(ការប្តូរប្រាក់ ត្រូវធ្វើតាមការបង្គាប់ឱ្យលក់)។ ប៉ុន្តែការអនុវត្តភាគច្រើនខុសៗគ្នាទៅតាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនីមួយៗ។ ឧទាហរណ៍ៈ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលមិនមានកូនបំណុលទី៣ ដូចជា សិទ្ធិប្រកាសនីយប័ត្រតក្កកម្មជាដើម អានុភាពនៃការរឹបអូសមិនមែនកើតឡើងនៅពេលធ្វើការបញ្ជូនទៅកូនបំណុលទី៣ ទេ គឺនឹងកើតឡើងនៅពេលបញ្ជូនទៅកូនបំណុលនៃការអនុវត្តវិញ។ ម៉្យាងវិញទៀត ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវចុះបញ្ជីជាដើម ត្រូវមានការផ្ទុកផ្តាក់ឱ្យចុះបញ្ជីស្តីពីការរឹបអូសដូចអចលនវត្ថុដែរ។ ចំពោះនីតិវិធីជាក់ស្តែងនីមួយៗ តុលាការត្រូវចាត់ចែងតាមប្រភេទនៃទ្រព្យសម្បត្តិនីមួយៗនោះ ដោយគិតពិចារណានូវបញ្ញត្តិស្តីពីការអនុវត្តចំពោះសិទ្ធិលើបំណុល។

[49] មាត្រា៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[50] មាត្រា៤១៤ នៃក្រមនីតិវិធីដដែល

[51] មាត្រា៤១៦ នៃក្រមនីតិវិធីដដែល

## ខ. តួនាទីក្នុងការអនុវត្តចំពោះអចលនវត្ថុ

### ខ.១. តួនាទីមុនពេលលក់អចលនវត្ថុ

អចលនវត្ថុ សំដៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនោះដែលជាសិទ្ធិរួម[52]។

តួនាទីរបស់អាជ្ញាសាលាលើអចលនវត្ថុមានដូចតទៅ៖

#### ខ.១.១. ការថែរក្សាគ្រប់គ្រងអចលនវត្ថុ

ប្រសិនបើកូនបំណុល ឬអ្នកកាន់កាប់អចលនវត្ថុបានប្រព្រឹត្តអំពើដែលធ្វើឱ្យតម្លៃនៃអចលនវត្ថុចុះថយ គួរឱ្យកត់សម្គាល់ ឬធ្វើឱ្យមានការលំបាកដល់ការលក់ ឬការប្រគល់អចលនវត្ថុ ឬបើមានការបារម្ភថាអ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាការអនុវត្តអាចហាមឃាត់ជនដែលបានប្រព្រឹត្តអំពើទាំងនោះ ឬជនដែលគេមានការបារម្ភថានឹងប្រព្រឹត្តអំពើទាំងនោះមិនឱ្យប្រព្រឹត្តអំពើនោះ ឬបង្គាប់ជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬបង្គាប់ឱ្យជននោះលះបង់នូវការកាន់កាប់អចលនវត្ថុ ហើយឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុនោះបានដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬអ្នកទិញដោយឱ្យដាក់ ឬមិនឱ្យដាក់ប្រាតិភោគ។ ប៉ុន្តែមានករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់ឱ្យជននោះប្រគល់អចលនវត្ថុឱ្យអាជ្ញាសាលាដើម្បីថែរក្សាគ្រប់គ្រងបាន។

#### ខ.១.២. ជំនួយឱ្យអ្នកវាយតម្លៃ

តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យអ្នកវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត។

ប្រសិនបើអ្នកវាយតម្លៃនោះ បំពេញតួនាទីរបស់ខ្លួនជួបនូវការលំបាក អ្នកវាយតម្លៃអាចស្នើសុំជំនួយពីអាជ្ញាសាលា តាមការអនុញ្ញាតរបស់តុលាការអនុវត្ត។ អាជ្ញាសាលាដែលត្រូវបានសុំឱ្យជួយនោះ អាចសុំជំនួយបន្តទៅនគរបាល ឬកងកម្លាំងផ្សេងៗទៀតដែលមានសមត្ថកិច្ច។ ក្នុងនាមជាជំនួយការឱ្យអ្នកវាយតម្លៃនេះ អាចធ្វើការចាត់ចែងចាំបាច់ ដើម្បីបើកទ្វារដែលបានបិទ នៅក្នុងករណីអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ[53]។

[52] មាត្រា៤១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[53] មាត្រា៤៣០ នៃក្រមនីតិវិធីដដែល

## ខ.២. តួនាទីពេលលក់អចលនវត្ថុ

### ខ.២.១. ការលក់ឡាយឡុងអចលនវត្ថុ

ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។ ការលក់ឡាយឡុងដោយស្រោមសំបុត្រ គឺជាវិធីដែលឱ្យអ្នកមានបំណងចង់ទិញ ដែលបានចូលរួមនៅកាលបរិច្ឆេទនៃការលក់ឡាយឡុង ស្នើសុំទិញដោយលិខិតឡាយឡុងដែលបានសរសេរនូវតម្លៃឡាយឡុង បន្ទាប់មកធ្វើការបើកលិខិត ហើយកំណត់អ្នកសុំទិញតម្លៃអតិបរមានៅទីនោះ។ បើតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ដោយសារមានអ្នកមានបំណងទិញផ្សេងទៀតពុំអាចដឹងបានសោះ អំពីការដែលអ្នកមានបំណងទិញបានដេញថ្លៃវត្ថុណាមួយដោយតម្លៃប៉ុន្មាននោះ សឹងតែពុំមានឱកាសប្រើស្នៀត ឬពិភាក្សាគ្នាទេ ហើយក៏ពុំមានការបារម្ភអំពីបរិយាកាសនៃកន្លែងលក់ ឬការដែលត្រូវគ្របសង្កត់ដោយគូប្រជែងដែលមានលក្ខណៈមិនល្អដែរ។ អាស្រ័យហេតុនេះ អាចគិតបានថា គឺជាវិធីដែលជាគោលដៅពេលលក់អចលនវត្ថុ។ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីលក់ដែលកំណត់អ្នកសុំទិញតម្លៃអតិបរមា ដោយឱ្យអ្នកមានបំណងទិញស្នើសុំទិញដោយផ្ទាល់នៅកាលបរិច្ឆេទ និងឱ្យប្រជែងថ្លៃនោះ។ ការលក់ឡាយឡុងដោយផ្ទាល់មាត់មានលក្ខណៈពិសេសត្រង់ចំណុចដែលអ្នកមានបំណងទិញដឹងនូវតម្លៃស្នើសុំរបស់គូប្រជែងឯទៀតទៅវិញទៅមក ហើយប្រជែងតម្លៃស្នើសុំជាលំដាប់លំដោយ។ វិធីនេះមានភាពងាយស្រួលក្នុងការស្នើសុំទិញ ហើយការប្រជែងត្រូវបានអនុវត្តផ្ទាល់ចំពោះមុខ ហេតុដូច្នេះមានគុណសម្បត្តិដែលអាចសង្ឃឹមនូវការលក់ដោយតម្លៃខ្ពស់ តែផ្ទុយទៅវិញមានគុណវិបត្តិដោយសារអ្នកមានបច្ចេកទេសជំនាញ និងមានបទពិសោធន៍ច្រើន មានប្រៀបជាងគូប្រជែងដទៃទៀត និងមានការលំបាកក្នុងការស្វែងរកការចូលរួមដោយជនទូទៅជាទូលំទូលាយ។

តុលាការអនុវត្តអាចកំណត់វិធីលក់ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ក្នុងករណីដែលអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។

ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ។

### ខ.២.២. ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់

នៅពេលធ្វើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ប្រសិនបើជនណាធ្វើសកម្មភាពរំខាន កុំឱ្យការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យរំខានដល់ជនដទៃទៀត ក្នុងការធ្វើសំណើទិញ ឬបានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ដោយត្រឹមត្រូវ ឬចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ ក្នុងករណីនេះ អាជ្ញាសាលាអាចហាមឃាត់ឱ្យជននោះចូលកន្លែងលក់ ឬអាចដេញជននោះចេញពីកន្លែងលក់ ឬអាចមិនឱ្យស្នើសុំទិញបាន។

## ខ.៣. តួនាទីក្រោយពេលលក់អចលនវត្ថុ

### ខ.៣.១. ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា

បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និងបានប្រកាសនូវនាម ឬនាមករណ៍របស់អ្នកទិញ និងថ្លៃលក់ឡាយឡុងនោះ។

បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានស្នើសុំទិញក្នុងតម្លៃអតិបរមាមានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនបានដេញថ្លៃពីមុនបានឡើយ។

បើអ្នកដេញថ្លៃដែលបានកំណត់ពីខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាត្រូវបានកំណត់ដោយការចាប់ឆ្នោត។ ចំណែកឯអ្នកដែលដេញថ្លៃដោយស្រោមសំបុត្រ ដែលធ្វើសំណើទិញក្នុងតម្លៃអតិបរមាមានច្រើននាក់ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ[54]។

### ខ.៣.២. ការធ្វើកំណត់ហេតុនៃការលក់ឡាយឡុង

បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។ កំណត់ហេតុនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម[55]៖

- សញ្ញាណនៃអចលនវត្ថុ
- កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់
- សញ្ញាណអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និងអ្នកតំណាង
- តម្លៃទិញរបស់អ្នកទិញក្នុងតម្លៃអតិបរមា
- ហេតុការណ៍នោះ និងស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
- មូលហេតុ និងវិធានការណ៍ដែលបានចាត់ធ្វើ បើបានចាត់វិធានការណ៍ដែលបានកំណត់ក្នុងការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់នោះ។

អាជ្ញាសាលា ត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬអ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។

[54] មាត្រា៥៣៩ កថាខណ្ឌទី១ ទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[55] មាត្រា៥៣៩ កថាខណ្ឌទី៤ ទី៥ នៃក្រមនីតិវិធីដដែល

### គ. តួនាទីក្នុងការអនុវត្តដោយបង្ខំចំពោះនាវា

នាវា សំដៅទៅលើជលយានដែលមានចំណុះសរុបជាតោន ស្មើនឹង និងលើសពី ២០(ម្ភៃ) តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងជលយានដែលមានចំណុះសរុបជាតោន ក្រោម ២០(ម្ភៃ) តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[56]។

#### គ.១. ការដកហូត និងការសងលិខិតបញ្ជាក់សញ្ជាតិនាវា

លិខិតបញ្ជាក់សញ្ជាតិនាវា សំដៅទៅលើឯកសារដែលបញ្ជាក់សញ្ជាតិរបស់នាវា និងឯកសារផ្សេងទៀតដែលចាំបាច់ ដើម្បីបើកបរនាវាដោយស្របច្បាប់។

ឯកសារដែលបញ្ជាក់សញ្ជាតិនាវា និងឯកសារផ្សេងទៀតដែលចាំបាច់បើកបរនាវាដោយស្របច្បាប់ ឧទាហរណ៍មានដូចជា៖

- លិខិតបញ្ជាក់សញ្ជាតិនាវា
- លិខិតអនុញ្ញាតឱ្យបើកបរ
- របាយការណ៍ស្តីពីដំណើរនាវា
- លិខិតត្រួតពិនិត្យនាវា
- បញ្ជីរាយនាមនាវិក ជាដើម។

ដើម្បីចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ តម្រូវឱ្យតុលាការបង្គាប់ទៅអាជ្ញាសាលា ឱ្យដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាមួយនឹងការចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។ ការរឹបអូសលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ មានគោលបំណងការពារកុំឱ្យនាវានោះចាកចេញពីទីកន្លែងដែលរឹបអូស និងរក្សាទុក។ បើមានដីកាសម្រេចចាប់ផ្តើមរួចហើយ នៅមុនពេលចេញដីកាសម្រេចចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះនាវា ហើយបើលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ត្រូវបានដកហូតដោយយោងតាមដីកាសម្រេចមុននោះ ការបង្គាប់ ឬមិនបង្គាប់ទៅអាជ្ញាសាលា គឺអាស្រ័យទៅលើស្ថានភាពពិតនៃប្រទេសកម្ពុជា។ ម៉្យាងទៀត ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនេះ មិនអាចប្តឹងជំទាស់បានទេ តែអាចធ្វើឧបាស្រ័យបាន ដោយការតវ៉ាចំពោះការអនុវត្ត។

នៅក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំខាងលើនេះ តុលាការអនុវត្តត្រូវប្រកាសអំពីការរឹបអូសនាវានោះ ជាប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ចំពោះការចេញដំណើរនៃនាវានោះ។

[56] មាត្រា៤៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

បើអាជ្ញាសាលាបានដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ឬនៅមុនពេលចុះបញ្ជីអំពីការរឹបអូស អានុភាពនៃការរឹបអូសនោះកើតឡើងនៅពេលដកហូត។

ការដកហូតលិខិតបញ្ជាក់នាវា ជាអាទិ៍ ខាងលើនេះ អាចអនុវត្តបានតែក្នុងករណីដែលតុលាការអនុវត្តចាប់ផ្ដើមនៃការលក់ដោយបង្ខំប៉ុណ្ណោះ។

ផ្ទុយទៅវិញ ការដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ក៏អាចធ្វើបានមុនពេលចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំបានដែរ គឺករណីដែលសាលាដំបូងមានការព្រួយបារម្ភថា នឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំចំពោះនាវានោះ។ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះត្រូវបានចុះបញ្ជី អាចចេញដីកាបង្គាប់ឱ្យកូនបំណុលប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាទៅតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។

ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់នាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាតាមករណីខាងលើនេះ នឹងពុំត្រូវបានអនុវត្តឡើយ បើហួសអំឡុងពេល ២ សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត[57]។ បើម្ចាស់បំណុលនៃការអនុវត្ត មិនបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា នៅក្នុងអំឡុងពេល ៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នោះទេ អាជ្ញាសាលាត្រូវសងលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នោះទៅឱ្យកូនបំណុលនៃការអនុវត្ត[58]។

### គ.២. ជំនួយឱ្យអ្នកវាយតម្លៃ

តុលាការអនុវត្តអាចជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃនាវានោះបាន ហើយអ្នកវាយតម្លៃអាចសុំជំនួយពីអាជ្ញាសាលាបាន លុះត្រាតែមានការអនុញ្ញាតពីតុលាការអនុវត្ត។

នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅក្នុងនាវា ឬអាចសួរសំណួរ ឬទាមទារឱ្យបង្ហាញឯកសារចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់នាវានោះបាន ហើយក្នុងករណីចាំបាច់ អាជ្ញាសាលាដែលត្រូវបានសុំជំនួយដោយអ្នកវាយតម្លៃនោះ អាចធ្វើការចាត់ចែងចាំបាច់ ដើម្បីបើកទ្វារដែលបានបិទនោះ។

[57] មាត្រា៤៥៩ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[58] មាត្រា៤៥៩ កថាខណ្ឌទី៧ នៃក្រមនីតិវិធីដដែល

**គ.៣. ការលក់ឡាយឡុងចំពោះនាវា**

ការលក់នាវាអាចធ្វើតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ឬតាមវិធីផ្សេងទៀត ដែលកំណត់ដោយតុលាការអនុវត្ត។ ក្នុងករណីធ្វើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់ថ្ងៃពេលវេលា និងទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ។

**គ.៤. ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់**

នៅពេលធ្វើការលក់នាវា ប្រសិនបើជនណាម្នាក់ធ្វើសកម្មភាពរំខាន ដល់ការអនុវត្តការលក់ដែលធ្វើឡើង ដោយពុំត្រឹមត្រូវនោះ ដោយធ្វើការរំខានដល់អ្នកដទៃក្នុងការធ្វើសំណើទិញ ឬបានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ ដោយមិនត្រឹមត្រូវ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលក្នុងកន្លែងលក់ ឬអាចដេញជននោះចេញពីកន្លែង លក់ ឬអាចមិនឱ្យជននោះធ្វើសំណើទិញបាន។

**កថាខណ្ឌទី ២ ៖ ការអនុវត្តតាមការចាត់តាំងរបស់សាលាដំបូងក្នុងការចាត់ចែងរក្សាការពារ**

គោលបំណងនៃការចាត់ចែងរក្សាការពារ គឺដើម្បីបង្ការនូវការអនុវត្តដោយបង្ខំដែលនឹងអាចធ្វើបាន ឬ ដែលនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬដោយសារមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ ដោយគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ ហេតុនេះហើយ ចាំបាច់ត្រូវធ្វើការចាត់ចែងរក្សាការពារកម្មវត្ថុនៃវិវាទនោះ តាមការស្នើសុំពីបុគ្គលដែលមានបំណងចង់ការពារសិទ្ធិ របស់ខ្លួន។

**ក. ស្ថាប័នចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន**

ការចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន ត្រូវធ្វើឡើងតាមរយៈស្ថាប័នដែលទទួលបន្ទុកចាត់ចែង រក្សាការពារជាបណ្តោះអាសន្ននោះ ដែលស្ថាប័ននេះរួមមាន តុលាការអនុវត្តការរក្សាការពារ និងអាជ្ញាសាលា។

ភាគីដែលមានបំណងចង់ធ្វើការរក្សាការពារ អាចដាក់ពាក្យសុំទៅស្ថាប័នណាមួយក្នុងចំណោមស្ថាប័ន ទាំងពីរដែលមានសមត្ថកិច្ច ដោយអាស្រ័យទៅលើកម្មវត្ថុនៃពាក្យសុំនោះ។

**ខ. ប្រភេទនៃការចាត់ចែងរក្សាការពារ**

ការចាត់ចែងរក្សាការពារត្រូវបានបែងចែកជា បី ប្រភេទ ដែលមានខ្លឹមសារដូចខាងក្រោម[59]៖

- ការរឹបអូសជាបណ្តោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់ កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឱ្យសង ជាប្រាក់។

[59] មាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។

ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន ត្រូវបានចែកទៅតាមលក្ខណៈនៃសិទ្ធិដែលបានរក្សាការពារនោះ គឺសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ឬក្រៅពីប្រាក់។ ប៉ុន្តែចំពោះខ្លឹមសារវិញ ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទមានចំណុចរួមមួយ គឺការចាត់ចែងទាំងពីរនេះ ធ្វើឡើងដើម្បីជាកម្មវត្ថុនៃវិវាទដែលមានដូចជា ការចាត់ចែងជាបណ្តោះអាសន្នដែលហាមការផ្ទេរការកាន់កាប់ចលនវត្ថុណាមួយ ឬដែលអាជ្ញាសាលាគ្រប់គ្រងចលនវត្ថុនោះដើម្បីរក្សាការពារនូវសិទ្ធិទាមទារឱ្យប្រគល់នូវចលនវត្ថុនោះ។

- ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន គឺការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្ន រហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ជាបន្ទាន់ ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ធ្វើឡើងដើម្បីជៀសវាងនូវបញ្ហាផ្សេងៗក្រៅពីការលំបាក ឬអលទ្ធភាពក្នុងការអនុវត្តដោយបង្ខំនាពេលអនាគត ក្នុងចំណោមការខូចខាត ឬការបាត់ប្រយោជន៍ដែលមកពីការយឺតយ៉ាវក្នុងការសម្រេចទំនាក់ទំនងសិទ្ធិជាស្ថាពរ។ ឧទាហរណ៍ៈ ដូចជាការចាត់ចែងជាបណ្តោះអាសន្នដែលរក្សាការពារឋានៈកម្មករ ឬការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យបង់ប្រាក់ខែជាបណ្តោះអាសន្ន ក្នុងករណីដែលមានវិវាទអំពីសុពលភាពនៃការដេញកម្មករនោះ។ ការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យបង់ប្រាក់ខែជាបណ្តោះអាសន្ន គឺជាការចាត់ចែងរក្សាការពារ ដើម្បីឱ្យទទួលនូវការស្កប់ចិត្តជាបណ្តោះអាសន្ន ចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ហេតុនេះបានជាគេហៅថា ការចាត់ចែងជាបណ្តោះអាសន្នដើម្បីស្កប់ចិត្ត។

### គ. សោហ៊ុយនៃការចាត់ចែងរក្សាការពារ

នៅពេលដែលអ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥ .០០០(ប្រាំពាន់) រៀល ទៅតុលាការដែលខ្លួនបានដាក់ពាក្យសុំនោះ។

ជាគោលការណ៍ សោហ៊ុយសម្រាប់ការចាត់ចែងរក្សាការពារ ដែលទាក់ទងនឹងបញ្ញត្តិស្តីពីប្រាក់ប្រដាប់ក្តីត្រូវយកមកអនុវត្ត[60]។ លើកលែងតែបញ្ញត្តិនៃពន្ធដាក់ពាក្យសុំ[61] និងតាមការបង្គាប់របស់តុលាការដែលឱ្យភាគី ឬអ្នកទាក់ទងនឹងរឿងក្តីបង់ប្រាក់ប្រដាប់ក្តីជាមុន និងការមិនព្រមបង់ជាមុនរបស់ភាគី តាមការបង្គាប់របស់តុលាការមុនចាប់ផ្តើមសកម្មភាពនីតិវិធី[62]។ មានន័យថាក្នុងនីតិវិធីរក្សាការពារ ការចេញសេចក្តីសម្រេចធ្វើការចាត់ចែងរក្សាការពារ និងការអនុវត្តរក្សាការពារ គឺជាកិច្ចការភ្ជាប់នឹងគ្នា ហេតុដូច្នេះចំពោះសោហ៊ុយសម្រាប់នីតិវិធីចេញដីកាសម្រេចស្តីពីការរក្សាការពារ ព្រមទាំងនីតិវិធីរក្សាការពារ សោហ៊ុយទាំងឡាយដូចជា ពន្ធនៃការដាក់ពាក្យសុំទៅតុលាការ និងទៅអាជ្ញាសាលា ប្រាក់ប្រដាប់ក្តីក្រៅពន្ធនៃការដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្តីភាគីជាបន្ទុករបស់ភាគីម្ខាងទៀត។ ប្រសិនបើតុលាការទទួលស្គាល់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារហើយជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ប្រសិនបើពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះ ត្រូវបានច្រានចោល។

ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តរក្សាការពារទៅតុលាការអនុវត្តរក្សាការពារ អ្នកដែលដាក់ពាក្យសុំត្រូវបង់ប្រាក់ជាមុននូវចំនួនទឹកប្រាក់ ដែលកំណត់ដោយតុលាការអនុវត្តរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តរក្សាការពារ។

ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលាការអនុវត្តរក្សាការពារអាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តរក្សាការពារ ឬលុបចោលនូវនីតិវិធីអនុវត្តរក្សាការពារបាន ដីកាសម្រេចលើកចោលនូវពាក្យសុំ អាចប្តឹងជំទាស់បាន ក្នុងករណីដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ចំពោះអាជ្ញាសាលា អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធតាមបញ្ញត្តិដែលបានកំណត់ផ្សេង។

### ឃ. ការអនុវត្តរក្សាការពារ

ការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ។ ប៉ុន្តែការអនុវត្តរក្សាការពារចំពោះ ឬសម្រាប់ជនក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត។

ការអនុវត្តរក្សាការពារមិនត្រូវធ្វើឡើយ បើអំឡុងពេល ២ សប្តាហ៍បានកន្លងហួស ចាប់គិតពីថ្ងៃដែលដីកាសម្រេចរក្សាការពារបានបញ្ជូនទៅម្ចាស់បំណុល ទោះបីនៅពេលដែលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារអាចធ្វើបានដែរ។

[60] គន្លឹទី១ ជំពូកទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[61] មាត្រា៦១ នៃក្រមនីតិវិធីដដែល

[62] មាត្រា៦២ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីដដែល

### ឃ.១. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។

អាជ្ញាសាលាត្រូវផ្ញើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ។

បើមានបារម្ភថា ចលនវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នត្រូវបានអនុវត្ត នឹងចុះតម្លៃយ៉ាងខ្លាំង ឬបើត្រូវការប្រើសោហ៊ុយច្រើនហួសហេតុ ដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុ[63] ដែលបានកំណត់តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ឬកូនបំណុល ហើយផ្ញើប្រាក់ដែលបានពីការលក់នោះ នៅតុលាការដែលខ្លួនស្ថិតនៅ។

ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះ៖

- ការដាក់ពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ដោយនៅក្នុងពាក្យសុំនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់អំពីទីកន្លែងដែលវត្ថុដែលត្រូវរឹបអូសនោះស្ថិតនៅ
- ការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត
- ការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត
- បទប្បញ្ញត្តិពិសេសស្តីពីរថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជី
- ការរួមបញ្ចូលរឿងក្តី
- ទំហំដែលការរឹបអូសមានអានុភាព
- ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស
- ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ
- ការហាមឃាត់មិនឱ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់
- ការលុបចោលនូវការរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថា មិនអាចលក់បាន។

### ឃ.២. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិ

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី៣ សងទៅកូនបំណុល។

[63] គន្លឹះទី៦ ជំពូកទី២ ផ្នែកទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលកំណត់តាមកថាខណ្ឌខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ។

ក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី៣ បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះភាគដែលលើសពីចំនួនប្រាក់នោះ។

ការរឹបអូសជាបណ្តោះអាសន្នតាមករណីខាងលើ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត។

ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល អាជ្ញាសាលាក្រោយពីបានទទួលនូវចលនវត្ថុពីកូនបំណុលតាមការទាមទាររបស់ម្ចាស់បំណុល ត្រូវធ្វើការលក់ចលនវត្ថុតាមនីតិវិធីលក់ចលនវត្ថុ ហើយត្រូវប្រគល់ប្រាក់ដែលបានមកពីការលក់នោះ ទៅតុលាការអនុវត្តរក្សាការពារ។

ការអនុវត្តរក្សាការពារចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងក្រៅពីចលនវត្ថុ អចលនវត្ថុ នាវា និងសិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស។

### ឃ.៣. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

ការរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬតាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅតុលាការអនុវត្តរក្សាការពារ ចំពោះរបៀបទាំងអស់នេះអាចអនុវត្តរួមគ្នាបាន[64]។

ចំពោះការរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ[65]។

ចំពោះការរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជី ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះ[66]៖

- ការដាក់ពាក្យសុំឱ្យអនុវត្តចំពោះនាវា ដោយនៅក្នុងពាក្យសុំ[67] ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរអំពីទីកន្លែងដែលនាវានោះស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬបរិបាលនាវានោះ និងទីកន្លែង

[64] មាត្រា៥៦៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[65] មាត្រា៥៦៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីដដែល

[66] មាត្រា៥៦៨ កថាខណ្ឌទី៤ នៃក្រមនីតិវិធីដដែល

ដែលមេបញ្ជាការ ឬបរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន និងត្រូវភ្ជាប់មកជាមួយនូវឯកសារចម្លងនៃសៀវភៅចុះបញ្ជីដែលមានសេចក្ដីបញ្ជាក់(ចំពោះនាវាដែលបានចុះបញ្ជី) ឬឯកសារដែលបញ្ជាក់ចំណុះនាវា ឬឯកសារបញ្ជាក់កម្មសិទ្ធិនាវារបស់កូនបំណុលនៃការអនុវត្ត(ចំពោះនាវាដែលមិនបានចុះបញ្ជី ឬនាវាផ្សេងទៀត ក្រៅពីនាវារបស់ប្រទេសកម្ពុជា)។

- ការលុបចោលនីតិវិធីលក់ជាបណ្ដោះអាសន្ន ដោយការវិនាសបាត់បង់នាវា ជាអាទិ៍
- ការផ្អកផ្ដាក់ឱ្យលុបការចុះបញ្ជីពីការរឹបអូស។

ចំពោះការរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតអនុវត្តបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះ៖

- ការភ្ជាប់មកជាមួយនូវឯកសារចម្លង នៃសៀវភៅចុះបញ្ជីដែលមានសេចក្ដីបញ្ជាក់ ឯកសារបញ្ជាក់ចំណុះនាវា និងឯកសារបញ្ជាក់កម្មសិទ្ធិនាវារបស់កូនបំណុលនៃការអនុវត្ត
- ដីកាសម្រេចលើកចោលពាក្យសុំការលក់ដោយបង្ខំ
- ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍
- ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ។

### ឃ.៤. ការអនុវត្តដូចគ្នា

បញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការរក្សាការពារ លុះត្រាតែមិនផ្ទុយពីលក្ខណៈនៃការអនុវត្តរក្សាការពារ មានដូចជា[68]៖

- ការធានាក្នុងការបំពេញតួនាទីរបស់អាជ្ញាសាលា
- អ្នកសង្កេតការណ៍
- ការអនុវត្តនៅថ្ងៃឈប់សម្រាក ឬពេលយប់
- ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍
- ការស្នើសុំជំនួយពីក្រសួងមានសមត្ថកិច្ច
- បញ្ញត្តិពិសេសស្ដីពីបណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ
- ការតវ៉ាចំពោះការអនុវត្ត
- បណ្ដឹងជំទាស់ចំពោះការសម្រេចលុបចោល ជាអាទិ៍
- អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ

[67] មាត្រា៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[68] គន្លឹះទី៦ នៃក្រមនីតិវិធីដដែល

- របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ(លើកលែងបញ្ញត្តិស្តីពីពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ)។

- ការអនុវត្តដោយបង្ខំ អាចធ្វើបានដោយចង្អុលអ្នកដែលជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត[69]

- ការផ្តល់រូបមន្តអនុវត្ត តាមពាក្យសុំរបស់ភាគីនៃការអនុវត្ត[70]

- ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត និងការប្រគល់នូវឯកសារចម្លង យថាភូតនៃលិខិតអនុវត្ត[71]

- ចំណុចដែលត្រូវសរសេរនៅក្នុងរូបមន្តអនុវត្ត[72]

- ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍[73]

- ការសរសេរចូលទៅក្នុងច្បាប់ដើម នៃលិខិតអនុវត្ត[74]

- ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍

- បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

- បណ្តឹងតវ៉ារបស់តតិយជន

- ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ា ចំពោះការទាមទារ ជាអាទិ៍[75]

- ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយ ជាអាទិ៍[76]

- ការសម្រេចសេចក្តីផ្អាកការអនុវត្ត ដោយការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍[77]

- ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ[78]។

[69] មាត្រា៣៥១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[70] មាត្រា៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីដដែល

[71] មាត្រា៣៥៥ កថាខណ្ឌទី១ និងទី៣ នៃក្រមនីតិវិធីដដែល

[72] មាត្រា៣៥៧ នៃក្រមនីតិវិធីដដែល

[73] មាត្រា៣៥៨ នៃក្រមនីតិវិធីដដែល

[74] មាត្រា៣៥៩ នៃក្រមនីតិវិធីដដែល

[75] មាត្រា៣៦៧ នៃក្រមនីតិវិធីដដែល

[76] មាត្រា៤៦៨ នៃក្រមនីតិវិធីដដែល

[77] មាត្រា៣៦៩ នៃក្រមនីតិវិធីដដែល

[78] មាត្រា៣៧០ នៃក្រមនីតិវិធីដដែល

**ខ. អានុភាពនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់**

បើតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និងបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលាដោយធ្វើការដកហូតការកាន់កាប់វត្ថុនោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាធ្វើការថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ អាជ្ញាសាលាត្រូវធ្វើការប្រកាសជាសាធារណៈថា កូនបំណុលត្រូវធ្វើការហាមឃាត់ការផ្ទេរការកាន់កាប់វត្ថុនោះ ហើយអាជ្ញាសាលាត្រូវគ្រប់គ្រងថែរក្សាវត្ថុនោះ ដោយបិទប្រកាសជាសាធារណៈតាមរបៀបដែលពុំងាយយកចេញ ឬតាមរបៀបសមរម្យផ្សេងទៀត។

បើការចាត់ចែងជាបណ្តោះអាសន្នដូចបានរៀបរាប់ខាងលើនេះត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្តី ប៉ុន្តែម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តចាត់ចែងជាបណ្តោះអាសន្នត្រូវបានធ្វើហើយ។

ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធ ក្រោយការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបានកំណត់ដូចនៅក្នុងចំណុចទី១ ខាងលើនេះ ត្រូវសន្មតថាកាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តចាត់ចែងជាបណ្តោះអាសន្ននោះ ត្រូវបានធ្វើហើយ។

# សេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវខាងលើបានបង្ហាញឱ្យឃើញថា ប្រធានបទស្តីពី **"តួនាទីអាជ្ញាសាលានៅព្រះរាជាណាចក្រកម្ពុជា"** គឺយើងអាចសន្និដ្ឋានបានថា អាជ្ញាសាលាមានតួនាទីយ៉ាងសំខាន់ ដូចជា តួនាទីដែលទាក់ទងនឹងការបញ្ជូនលិខិត និងឯកសារមួយចំនួនដែលបានកំណត់ដោយច្បាប់ នៅក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ។ ព្រមទាំងដើរតួនាទីយ៉ាងសំខាន់ ដើម្បីកាត់បន្ថយការរាំងស្ទះ និងការកកស្ទះសំណុំរឿងក្តីក្នុងតុលាការ ក្នុងស្ថាប័នអនុវត្តដោយផ្ទាល់ផង និងជាស្ថាប័នជំនួយដល់ តុលាការផងដែរ ដូចជានៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ តាមរយៈតួនាទីទាំងនេះឃើញថា ជួយដល់តុលាការឱ្យមានលក្ខណៈកាន់តែប្រសើរឡើង និងប្រកបដោយប្រសិទ្ធភាពខ្ពស់ទាក់ទងការបញ្ជូន និងការជូនដំណឹងតាមផ្លូវតុលាការអនុវត្តតាមនីតិវិធីមួយច្បាស់លាស់ ដូចជាមានស្ថាប័នដែលត្រូវទទួលបន្ទុកកិច្ចការបញ្ជូន និងប្រតិបត្តិការបញ្ជូនត្រឹមត្រូវច្បាស់លាស់ ស្របតាមនីតិវិធីច្បាប់ជាធរមាន។ ក្នុងករណីនេះផងដែរ អាជ្ញាសាលាមានតួនាទីជាស្ថាប័នអនុវត្ត និងជាជំនួយឱ្យស្ថាប័ន តុលាការ ក្នុងការអនុវត្តសេចក្តីសម្រេច ពោលគឺជាសេនាធិការរបស់តុលាការ។ ក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានតួនាទីក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។ រីឯក្នុងឋានៈជាជំនួយឱ្យស្ថាប័នតុលាការ អាជ្ញាសាលាត្រូវធ្វើការចាត់ចែងការអនុវត្តសេចក្តីសម្រេច ដូចជាការអនុវត្តសាលក្រម សាលដីកា ឬដីកាផ្សេងៗទៀត។

ម៉្យាងវិញទៀត តួនាទីរបស់អាជ្ញាសាលា គឺមានសារៈសំខាន់ណាស់ក្នុងការជួយពន្លឿននីតិវិធីនៃការអនុវត្ត ទាំងឡាយឱ្យកាន់តែមានភាពឆាប់រហ័ស និងមានភាពងាយស្រួលនៅក្នុងការអនុវត្ត។ កាលណានីតិវិធីនៃការបញ្ជូន និងការអនុវត្តសេចក្តីសម្រេចរបស់តុលាការប្រព្រឹត្តទៅបានល្អ នោះនឹងធ្វើឱ្យស្ថាប័នយុត្តាធិការមានកិត្យានុភាព និងទទួលបាននូវការគោរព ព្រមទាំងមាននូវទំនុកចិត្តពីប្រជាពលរដ្ឋកាន់តែខ្លាំងឡើងៗ។ ចំពោះវត្តមានរបស់អាជ្ញាសាលានៅក្នុងសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជានៅតាមបណ្តាខេត្ត-ក្រុង នានា គឺជាផលប្រយោជន៍មួយដ៏ប្រសើរសម្រាប់ស្ថាប័នតុលាការ ព្រមទាំងភាគី និងជនដែលពាក់ព័ន្ធនៅក្នុងរឿងក្តីទាំងឡាយ ព្រោះដូចបានរៀបរាប់ខាងលើស្ថាប័នអាជ្ញាសាលា គឺមានតួនាទីសំខាន់ក្នុងការចុះអនុវត្តនូវកិច្ចការរបស់ខ្លួនតាមពាក្យសុំរបស់ភាគី ឬតាមបង្គាប់របស់តុលាការអនុវត្ត ដើម្បីអនុវត្តនូវតួនាទីដែលចាំបាច់ក្នុងការធ្វើឱ្យនីតិវិធីដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនមានប្រសិទ្ធភាព និងមិនប៉ះពាល់ដល់ផលប្រយោជន៍របស់គូភាគីនៃរឿងក្តីនោះទេ។

ជារួមមក មន្ត្រីអាជ្ញាសាលា គឺពិតជាមានតួនាទីយ៉ាងសំខាន់ណាស់ ដើម្បីជួយឱ្យដំណើរការនីតិវិធីរបស់តុលាការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព មានភាពឆាប់រហ័ស និងមិនធ្វើឱ្យខាតពេលវេលា និងប្រយោជន៍របស់គូភាគីឡើយ។

# អនុសាសន៍

ក្រោយពីបានឆ្លងកាត់តាមការស្រាវជ្រាវ និងការបកស្រាយជាច្រើនអំពី "**តួនាទីអាជ្ញាសាលានៅព្រះរាជាណាចក្រកម្ពុជា**"។ យើងខ្ញុំបានសង្កេតឃើញថា តួនាទីរបស់អាជ្ញាសាលាពិតជាមានសារៈសំខាន់ណាស់ នៅក្នុងការជួយសម្រួលដល់ស្ថាប័នតុលាការ និងជួយសម្រួលដល់ការអនុវត្តនីតិវិធីនៃការអនុវត្តបានឆាប់រហ័ស និងមានភាពងាយស្រួល ទាំងអស់នោះដូចជា ការជួយដល់ការងាររបស់តុលាការដែលទាក់ទងនឹងការបញ្ជូននូវលិខិត ឬឯកសារមួយចំនួន ដែលជៀសវាងការយឺតយ៉ាវដល់នីតិវិធី ជាដើម។ ជាក់ស្ដែងនៅក្នុងនោះផងដែរ អាជ្ញាសាលាក៏បានជួបប្រទះនូវផលវិបាកមួយចំនួនដូចដែលបានរៀបរាប់ខាងក្រោមនេះ៖

១. ផលវិបាកនៅក្នុងការកង្វះអាជ្ញាសាលា ដោយជាក់ស្ដែងមន្ត្រីអាជ្ញាសាលាមានទើបតែមួយជំនាន់តែប៉ុណ្ណោះ ដែលបានទទួលការបណ្ដុះបណ្ដាលដោយសាលាភូមិន្ទអាជ្ញាសាលា និងបានក្លាយជាមន្ត្រីអាជ្ញា-សាលា ប៉ុន្តែចំនួនមន្ត្រីអាជ្ញាសាលាដែលបានជាប់នៅក្នុងជំនាន់ទី ១ នេះ គឺនៅមានចំនួនខ្វះខាតច្រើន ដោយខេត្ត-ក្រុង នៅព្រះរាជាណាចក្រកម្ពុជាមួយចំនួនធំនូវពុំទាន់មានមន្ត្រីអាជ្ញាសាលា នៅតាមសាលាដំបូងខេត្ត-ក្រុង នោះនៅឡើយ។

២. ផលវិបាករបស់អាជ្ញាសាលាក្នុងពេលចុះអនុវត្ត ដោយនៅពេលដែលចុះទៅអនុវត្ត គឺត្រូវមានការស្នើសុំកម្លាំងចូលរួមអនុវត្ត ហើយនីតិវិធីស្នើសុំកម្លាំងទៅស្ថាប័នមានសមត្ថកិច្ចមានភាពខុសគ្នា តាមដែនដីរដ្ឋបាលនីមួយៗ ដែលការធ្វើបែបនេះ ធ្វើឱ្យមានការចំណាយពេលវេលាច្រើន និងធ្វើឱ្យមានការយឺតយ៉ាវនីតិវិធីផងដែរ។ រីឯករណីមួយទៀតគឺ មានការប្រឆាំងនិងការអនុវត្ត ដោយភាគីចាញ់ក្ដី(កូនបំណុលនៃការអនុវត្ត) តែងតែរកវិធីដែលអាចរារាំងដល់ការអនុវត្ត ហើយពេលខ្លះអាចឈានដល់ការប្រើអំពើហិង្សាទៀតផង ឬមួយក៏កម្មវត្ថុនៃការអនុវត្តត្រូវបានបាត់បង់ ឬផ្លាស់ប្ដូរទីតាំង ឬបានផ្ទេរទៅបុគ្គលផ្សេង ឬក៏មិនមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ឬការសហការពីកូនបំណុលជាដើម។

៣. ផលវិបាកលើបញ្ហាសោហ៊ុយរបស់អាជ្ញាសាលា ដោយសារមិនទាន់មានច្បាប់ស្ដីពីលក្ខន្តិកៈអាជ្ញា-សាលា ការគិតអំពីការចំណាយក្នុងការអនុវត្ត ត្រូវធ្វើឡើងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសលេខ ៣០ ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលារបស់ក្រសួងយុត្តិធម៌(ប្រការ១៣ និង១៤)។ ពន្ធដាក់ពាក្យសុំ ៥.០០០ (ប្រាំពាន់) រៀល រីឯសោហ៊ុយក្រៅពីពន្ធ គឺមានកំណត់នៅក្នុងប្រការ១៤ នៃប្រកាសនេះ។ ចំពោះការកំណត់សោហ៊ុយក្រៅពន្ធត្រូវកំណត់ទៅតាមភាពជាក់ស្ដែង និងភាពចាំបាច់តែប៉ុណ្ណោះ។

ដូច្នេះហើយ ដោយមើលឃើញពីបញ្ហាដែលជាផលវិបាករបស់អាជ្ញាសាលា ដែលកំពុងតែជួបប្រទះ យើងខ្ញុំយល់ថាដើម្បីធ្វើឱ្យកិច្ចការរបស់អាជ្ញាសាលាប្រព្រឹត្តទៅមានភាពល្អប្រសើរ គឺត្រូវឱ្យមានការចូលរួមសហការ

ពីស្ថាប័នដែលពាក់ព័ន្ធ ដូចជាកងកម្លាំងសាធារណៈ ជាដើម ក្នុងការជួយសម្រួលដល់ការអនុវត្តនីតិវិធីដែលច្បាប់បានកំណត់។ មិនត្រឹមតែប៉ុណ្ណោះ យើងខ្ញុំ សូមគាំទ្រនូវការបង្កើតឱ្យមានច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលាឱ្យបានឆាប់រហ័ស និងមានការបណ្តុះបណ្តាលជាបន្តនូវសិស្សអាជ្ញាសាលា ដើម្បីឱ្យក្លាយជាមន្ត្រីអាជ្ញាសាលាដ៏មានជំនាញ ក្នុងការបំពេញកិច្ចការនៅស្ថាប័នតុលាការសាលាដំបូងគ្រប់រាជធានី ខេត្ត-ក្រុង ដោយសារតែបច្ចុប្បន្ននេះមន្ត្រីអាជ្ញាសាលានៅមានការខ្វះខាតច្រើន ដោយសារខេត្ត-ក្រុង មួយចំនួននៅមិនទាន់មានមន្ត្រីអាជ្ញាសាលា ដើម្បីអនុវត្តកិច្ចនីតិវិធីដែលជាកិច្ចការរបស់អាជ្ញាត្រូវធ្វើនៅឡើយទេ។ម្យ៉ាងវិញទៀត សូមសំណូមពរឱ្យមានការផ្សព្វផ្សាយណែនាំ និងពន្យល់បន្ថែមចំពោះសាធារណៈជនឱ្យបានយល់ដឹងកាន់តែច្បាស់ផងដែរអំពីតួនាទី ភារកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តដែលស្របទៅនឹងច្បាប់ ដើម្បីការពារនូវផលប្រយោជន៍របស់បុគ្គលដែលជាម្ចាស់បំណុលនៃការអនុវត្ត។

# ឯកសារយោង

**ក. បទដ្ឋានគតិយុត្ត**

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

៣. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៤. អនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ "ស្តីពីការបង្កើតសាលាភូមិន្ទអាជ្ញាសាលា"

៥. ប្រកាសលេខ៣០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ "ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា"

៦. ប្រកាសលេខ០៦៦ កយ.ប្រក/១៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងយុត្តិធម៌ "ស្តីពីការតាំងស៊ប់មន្ត្រីអាជ្ញាសាលាក្នុងក្របខណ្ឌ"

៧. ប្រកាសលេខ០៦២ កយ.ប្រក/១៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ "ស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌"

៨. លិខិតណែនាំលេខ១៦៨ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ "ស្តីពីបែបបទនៃការអនុវត្តដោយបង្ខំ និងការចាត់ចែងលើមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា" របស់ទីស្តីការក្រសួងយុត្តិធម៌

**ខ. សេចក្តីព្រាងច្បាប់លើកទី៣ "ស្តីពីអាជ្ញាសាលា" ឆ្នាំ២០១២**

**គ. ឯកសារផ្សេងៗទៀត**

១. សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

២. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ឆ្នាំ២០០៨ "ស្តីពីការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ"

៣. វចនានុក្រមអេឡិចត្រូនិចខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ឆ្នាំ២០១១

៤. សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ "វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ" បោះពុម្ពលើកទី២ នៅរាជធានីភ្នំពេញដោយលោក អ៊ី ប៉ូរ៉ា សុភាវត្តី ឆ្នាំ២០១៦

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឧបសម្ព័ន្ធ | ចំនួន |
|---|---|---|
| **កិច្ចការផ្ដាច់មុខរបស់អាជ្ញាសាលា** | | |
| ០១ | ទទួលពាក្យសុំ | ០២ សន្លឹក |
| ០២ | លិខិតស្នើសុំកម្លាំងមានសមត្ថកិច្ច | ០២ សន្លឹក |
| ០៣ | កំណត់ហេតុអនុវត្ត | ០២ សន្លឹក |
| **កិច្ចការអាជ្ញាសាលាក្នុងកំឡុងពេលអនុវត្ត** | | |
| ០១ | បញ្ជីវត្តមានចូលរួមអនុវត្ត | ០១ សន្លឹក |
| ០២ | កំណត់ហេតុស្ដីពីការស្រាវជ្រាវដីកាបង្គាប់ឱ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ | ០២ សន្លឹក |
| ០៣ | របាយការណ៍ពីការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ | ០១ សន្លឹក |
| **សមត្ថកិច្ចផ្ដាច់មុខក្នុងរឿងរឹបអូសលក់ដោយបង្ខំ** | | |
| ០១ | លិខិតជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្ត | ០២ សន្លឹក |
| ០២ | លិខិតជូនដំណឹងទៅម្ចាស់បំណុល | ០១ សន្លឹក |
| ០៣ | លិខិតជូនដំណឹងទៅមេធាវីម្ចាស់បំណុល | ០១ សន្លឹក |
| ០៤ | លិខិតជូនដំណឹងទៅកូនបំណុល | ០១ សន្លឹក |
| ០៥ | លិខិតជូនដំណឹងទៅមេធាវីកូនបំណុល | ០២ សន្លឹក |
| ០៦ | កំណត់ហេតុស្ដីពីការលក់ឡាយឡុងដោយស្រោមសំបុត្រ | ០១ សន្លឹក |
| ០៧ | របាយការណ៍ស្ដីពីការអនុវត្តការលក់ | ០១ សន្លឹក |
| **ការបញ្ជូននៅក្នុងរឿងព្រហ្មទណ្ឌរបស់អយ្យការ** | | |
| ០១ | ដីកាអញ្ជើញឱ្យចូលរួមសវនាការ | ០២ សន្លឹក |
| ០២ | ដីកាកោះ | ០២ សន្លឹក |
| **តួនាទីក្នុងការអនុវត្តដីកាសម្រេចរបស់តុលាការអនុវត្ត** | | |
| ០១ | ដីកាសម្រេចអនុញ្ញាតឱ្យអនុវត្តជំនួស | ០២ សន្លឹក |
| ០២ | ដីកាសម្រេចរក្សាការពារ | ០៣ សន្លឹក |
| ០៣ | ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន | ០១ សន្លឹក |

| | | |
|---|---|---|
| ០៤ | ដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ | ០១ សន្លឹក |
| ០៥ | ដីកាសម្រេចតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលាដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ | ០១ សន្លឹក |
| ០៦ | ដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ | ០១ សន្លឹក |
| ០៧ | ដីកាសម្រេចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តប្រើចលនវត្ថុ ឬលុបចោលការអនុញ្ញាត | ០១ សន្លឹក |
| ០៨ | ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវរឹបអូស | ០១ សន្លឹក |
| ០៩ | ដីកាសម្រេចទាមទារឱ្យចែកចំណែក | ០១ សន្លឹក |
| ១០ | ដីកាសម្រេចបង្គាប់ឱ្យលក់ | ០១ សន្លឹក |
| ១១ | ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ | ០១ សន្លឹក |
| ១២ | ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា | ០១ សន្លឹក |
| ១៣ | ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ | ០១ សន្លឹក |